# ពិធីការបើកឡើងវិញសម្រាប់សាលារៀន K-12៖ ឧបសម្ព័ន្ធ T1

**បច្ចុប្បន្នភាពថ្មីៗ -** (ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿង)

**12/28/20៖**

- រយៈពេលនៅដាច់ពីគេដែលបានតម្រូវសម្រាប់បុគ្គលដែលបានប៉ះពាល់ជិតស្និទ្ធជាមួយមនុស្សដែលបានធ្វើរោគវិនិច្ឆ័យថាមានជំងឺ COVID-19 ត្រូវបានកាត់បន្ថយ។ អ្នកប៉ះពាល់ជិតស្និទ្ធដែលមិនចេញរោគសញ្ញាអាចត្រូវបានដោះលែងពីការនៅដាច់ពីគេបន្ទាប់ពីថ្ងៃទី 10 ប៉ុន្តែត្រូវតែបន្តតាមដានសុខភាពរបស់ខ្លួន និងគោរពតាមការប្រុងប្រយ័ត្នបង្ការជំងឺ COVID-19 រហូតដល់ថ្ងៃទី 14។
- សាលារៀនត្រូវបានតម្រូវឲ្យជូនដំណឹងដល់ DPH អំពីករណីជំងឺ COVID-19 ទាំងអស់ក្នុងចំណោមបុគ្គលិក និងកុមារដែលបានស្ថិតនៅសាលារៀននៅចំណុចណាមួយក្នុងរយៈពេល 14 ថ្ងៃមុនពេលធ្លាក់ខ្លួនឈឺ។ ករណីដែលបានស្ថិតនៅលើបរិវេណសាលាលើកចុងក្រោយលើសរយៈពេល 14 ថ្ងៃមុនពេលធ្លាក់ខ្លួនឈឺ មិនចាំបាច់ធ្វើការរាយការណ៍ទៅកាន់ DPH ដោយស្ថាប័នសាលារៀន K-12 ឡើយ។
- ផ្នែក C ត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីឲ្យស្របទៅតាមផ្លូវនៃការត្រួតពិនិត្យរោគសញ្ញា និងការប៉ះពាល់សម្រាប់បុគ្គលនៅគ្រឹះស្ថានអប់រំពី DPH។
- បានបញ្ជាក់ថា បើសិនជាសាលារៀនមានការផ្ទុះជំងឺ កម្មវិធីកុមារផ្សេងៗទៀតដែលកំពុងធ្វើប្រតិបត្តិការនៅលើអគារសាលារៀនមុនពេល ក្នុងអំឡុងពេល និងក្រោយម៉ោងសិក្សាក៏ត្រូវតែបិទផងដែរ ដោយអនុលោមតាមសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលឲ្យនៅផ្ទះមានសុវត្ថិភាពជាងដែលមានគោលដៅបណ្តោះអាសន្នដើម្បីគ្រប់គ្រង ជំងឺ COVID-19 មានប្រសិទ្ធភាពនៅវេលាម៉ោង 12:01 អធ្រាត្រថ្ងៃទី 1 ខែធ្នូឆ្នាំ 2020 រហូតដល់មានការជូនដំណឹងជាថ្មី។
- បុគ្គលិកត្រូវតែពាក់របាំងមុខ នៅពេលពួកគេស្ថិតនៅបន្ទប់តូច។
- បន្ទប់សម្រាក បានបិទផ្សាយដែនកំណត់ចំនួនមនុស្ស ហើយកន្លែងអង្គុយត្រូវបានរៀបចំដើម្បីឲ្យធានាបានថាបុគ្គលិកអាចរក្សាគំលាតរាងកាយ 6 ហ្វីតពីគ្នា។

**11/28/20៖** សាលារៀនដែលត្រូវបានកំណត់ដោយនាយកដ្ឋានសុខភាពសាធារណៈថាមានការផ្ទុះជំងឺ (3 ករណីឬច្រើនជាងនេះក្នុងពេល 14 ថ្ងៃ) ត្រូវតែបិទទ្វាររយៈពេល 14 ថ្ងៃដោយអនុលោមតាមសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលឲ្យនៅផ្ទះមានសុវត្ថិភាពជាងមានគោលដៅជាបណ្តោះអាសន្នដើម្បីគ្រប់គ្រងជំងឺ COVID-19 មានប្រសិទ្ធភាពនៅវេលាម៉ោង 12:01 អធ្រាត្រថ្ងៃទី 1 ខែធ្នូឆ្នាំ 2020 រហូតដល់មានការជូនដំណឹងជាថ្មី។ បានបន្ថែមតំណទៅកាន់ TK-12 COVID-19 Toolkit។

នាយកដ្ឋានសុខភាពសាធារណៈរបស់ខោនធី Los Angeles កំពុងអនុវត្តវិធីសាស្ត្រតាមដំណាក់កាល ដែលបានគាំទ្រដោយវិទ្យាសាស្ត្រ និងជំនាញការសុខភាពសាធារណៈដើម្បីអនុញ្ញាតឲ្យសាលារៀនដែលបម្រើសេវាដល់សិស្សចាប់ពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី 12 បើកដំណើរការឡើងវិញដោយសុវត្ថិភាព។ បន្ថែមលើល័ក្ខខ័ណ្ឌទៅលើសាលារៀនដែលបានដាក់ចុះដោយមន្ត្រីសុខាភិបាលសាធារណៈរបស់រដ្ឋ និងនាយកដ្ឋានអប់រំរដ្ឋ California សាលារៀនក៏ត្រូវតែគោរពតាមពិធីការស្តីពីសុវត្ថិភាពបុគ្គលិក និងសិស្ស និងការគ្រប់គ្រងការឆ្លងជំងឺទាំងនេះផងដែរ។

ចូរកត់សម្គាល់ថា ដោយអនុលោមតាមសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលឲ្យនៅផ្ទះមានសុវត្ថិភាពជាងដែលមានគោលដៅបណ្តោះអាសន្ន សាលារៀនដែលត្រូវបានកំណត់ដោយនាយកដ្ឋានសុខភាពសាធារណៈថាមានការផ្ទុះជំងឺ (3 ករណីឬច្រើនជាងនេះក្នុងរយៈពេល 14 ថ្ងៃ) ត្រូវតែបិទទ្វាររយៈពេល 14 ថ្ងៃ។ ល័ក្ខខ័ណ្ឌតម្រូវឲ្យបិទនេះ អនុវត្តចំពោះកម្មវិធីកុមារដែលកំពុងធ្វើប្រតិបត្តិការនៅលើអគារសាលាមុនពេល អំឡុងពេល ឬបន្ទាប់ពីម៉ោងសិក្សាធម្មតា។ វារាប់បញ្ចូល តែមិនដាក់កម្រិតត្រឹម ការថែទាំនៅពេលថ្ងៃសម្រាប់កុមារគ្រប់អាយុចូលរៀន កន្លែងបោះតង់ និងកម្មវិធីកីឡាយុវជន។

សូមកត់សម្គាល់៖ ឯកសារនេះអាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាពនៅពេលដែលមានព័ត៌មាន និងធនធានថ្មីៗ។ សូមចូលទៅកាន់ http://www.ph.lacounty.gov/media/Coronavirus/ សម្រាប់បច្ចុប្បន្នភាពទៅលើឯកសារនេះ។

ឯកសារនេះចាប់ផ្តើមជាមួយការពិភាក្សាអំពីការផ្តល់ជូនបច្ចុប្បន្នសម្រាប់ការអប់រំនៅលើបរិវេណសាលាក្នុងខោនធី Los Angeles បន្ទាប់មកព័ត៌មានអំពីយុទ្ធសាស្ត្រសុវត្ថិភាពជាក់លាក់សម្រាប់បរិស្ថានសាលារៀន។

បញ្ជីត្រួតពិនិត្យបើកឡើងវិញ TK-12 ចាប់ផ្តើមនៅលើទំព័រទី 4 និងផ្តល់ជូនវិធានការណ៍សុវត្ថិភាពនៅក្នុងប្រាំផ្នែក៖

(1) គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក និងសិស្ស

(2) វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ

(3) វិធានការណ៍ដើម្បីធានាបាននូវការគ្រប់គ្រងការឆ្លងជំងឺ

(4) ការទំនាក់ទំនងជាមួយបុគ្គលិក សិស្ស ក៏ដូចជាគ្រួសារសិស្ស និងសាធារណៈជន។

(5) វិធានការណ៍ដើម្បីធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

ចំណុចសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយ នៅពេលដែលទីកន្លែងរបស់អ្នកបង្កើតពិធីការបើកឡើងវិញណាមួយ។ សាលារៀនត្រូវតែដាក់ចុះនូវវិធានការណ៍ដែលអាចអនុវត្តបានទាំងអស់ ដែលមានរាយនៅខាងក្រោម និងត្រូវត្រៀមខ្លួនដើម្បីពន្យល់ពីមូលហេតុក្នុងករណីវិធានការណ៍ណាមួយ មិនត្រូវបានអនុវត្ត ដោយសារមិនសមស្របសម្រាប់ទីកន្លែង។

**ការណែនាំពិសេសសម្រាប់ទីកន្លែង TK-12**

សាលារៀន K-12 ទាំងអស់នៅក្នុងខោនធីនៃរដ្ឋ California ដែលស្ថិតនៅក្នុងលំដាប់ទី 1 នៃផែនការដើម្បីសេដ្ឋកិច្ចមានសុវត្ថិភាពជាងមុន (Blueprint for a Safer Economy) ~~របស់រដ្ឋរួមទាំង ខោនធី Los Angeles ត្រូវបានហាមឃាត់~~ មិនឲ្យបើកការបង្រៀនដោយផ្ទាល់ឡើយ។ ក្នុងអំឡុងពេលនេះ នៅពេលដែលសាលារៀនជាទូទៅត្រូវបានដាក់កម្រិតត្រឹមការសិក្សាពីចម្ងាយ កម្មវិធីនៅនឹងកន្លែងចំនួនបួនប្រភេទត្រូវបានអនុញ្ញាត។ ដោយអនុលោមតាមសេចក្តីបង្គាប់នេះ និងក្រៅពីករណីលើកលែងទាំងនេះ សាលារៀន K-12 នៅក្នុងខោនធី Los Angeles អាចបើកដំណើរការសម្រាប់តែការសិក្សាពីចម្ងាយប៉ុណ្ណោះ។ ក្នុងអំឡុងពេលនេះ និយោជិកនិងបុគ្គលិក ដូចបានកំណត់ខាងក្រោម អាចចូលធ្វើការនៅអគារសាលារៀន ដើម្បីគាំទ្រប្រតិបត្តិការសំខាន់ៗ អនុវត្តការសិក្សាពីចម្ងាយ ឬបំពេញកិច្ចការនៅក្នុងការសិក្សានៅលើបរិវេណសាលាដែលបានអនុញ្ញាតទាំងបួនប្រភេទ។ ទាំងនេះគឺ៖

- **ការថែទាំនៅពេលថ្ងៃសម្រាប់កុមារគ្រប់អាយុចូលរៀន និង/ឬកម្មវិធីថែទាំដែលស្ថិតនៅក្នុងសាលារៀន**
    - LEAs និងសាលារៀនដែលផ្តល់សេវាកម្មថែទាំនៅពេលថ្ងៃសម្រាប់កុមារនៅសាលារៀន ត្រូវតែអនុលោមតាមពិធីការ DPH សម្រាប់កម្មវិធីផ្តល់ការថែទាំនៅពេលថ្ងៃសម្រាប់កុមារគ្រប់អាយុចូលរៀន (Programs Providing Day Care for School-Aged  Children)ឬការណែនាំសម្រាប់អ្នកផ្តល់សេវា ECE ( Guidance for ECE Providers)។ កម្មវិធីដែលមានបំណងផ្តល់ការថែទាំនៅពេលថ្ងៃសម្រាប់កុមារគ្រប់អាយុចូលរៀន គួរទាក់ទងជាមួយ ការិយាល័យក្នុងតំបន់នៃស្ថាប័នផ្តល់អាជ្ញាប័ណ្ណលើការថែទាំក្នុងសហគមន៍ដើម្បីសាកសួរអំពីការដែលអាចមានការលើកលែងសម្រាប់ទីកន្លែងថែទាំកុមារ ដែលមានអាជ្ញាប័ណ្ណ និងអ្នកផ្តល់សេវាដែលរួចផុតពីអាជ្ញាប័ណ្ណដោយសារជំងឺ COVID-19។ សម្រាប់ព័ត៌មានបន្ថែម សូមមើល PIN 20-22-CCP។
    - សាលារៀនដែលផ្តល់កម្មវិធីថែទាំកុមារសម្រាប់កុមារគ្រប់អាយុចូលរៀននៅលើបរិវេណសាលារបស់ខ្លួនត្រូវតែធ្វើការជូនដំណឹងសម្រាប់ សេវាកម្មថែទាំកុមារសម្រាប់កុមារគ្រប់អាយុចូលរៀននៅលើទីកន្លែងសាលារៀន K-12 (Child Care Services for School-aged Children on K-12 School sites) ជាមួយ LAC DPH។

- **សេវាកម្មឯកទេសសម្រាប់អនុក្រុមកុមារដែលបានកំណត់ ដែលត្រូវការសេវាកម្ម និងការគាំទ្រដោយផ្ទាល់**
    - LEAs និងសាលារៀនមិនត្រូវបានតម្រូវឲ្យផ្តល់សេវាកម្មឯកទេសដោយផ្ទាល់ឡើយ ប៉ុន្តែសាលារៀនទាំងឡាយដែលធ្វើដូច្នោះ អាចបម្រើសេវាដល់សិស្សដែលមាន IEPs សិស្សដែលជាអ្នកសិក្សាភាសាអង់គ្លេស និងសិស្សដែលមានតម្រូវការមិនអាចបំពេញតាមរយៈកម្មវិធីបង្រៀនដោយមិនជួបផ្ទាល់បាន។ សិស្សទាំងនេះ អាចទទួលសេវាតាមការចាំបាច់ ក្នុងករណីដែលចំនួនសិស្សទាំងអស់ដែលមានវត្តមាននៅនឹងកន្លែងមិនលើសពី 25% នៃចំនួនសិស្សសរុបក្នុងពេលណាមួយ។ ករណីលើកលែងមួយចំពោះវិធានការណ៍ 25% នេះគឺសាលារៀនដែលបានទទួលការលើកលែងដើម្បីនាំសិស្សនៅក្នុងថ្នាក់ទី TK – 2 មកវិញសម្រាប់ការបង្រៀនដោយផ្ទាល់។ សាលារៀនដែលបានទទួលការលើកលែង ត្រូវបានអនុញ្ញាតឲ្យនាំសិស្សទាំងអស់នៅក្នុងថ្នាក់ TK – 2 មកកាន់បរិវេណសាលារៀនវិញដោយរាប់បញ្ចូលទាំងសិស្សដែលមានតម្រូវការខ្ពស់នៅក្នុងថ្នាក់ទាំងនោះ។ ក្នុងស្ថានភាពនេះ សាលារៀនក៏អាចនាំសិស្សរហូតដល់ 25% នៃចំនួនសិស្សសរុបដែលបានចុះឈ្មោះក្នុងថ្នាក់ទី 3 និងថ្នាក់ខ្ពស់ជាងនេះក្នុងពេលណាមួយសម្រាប់ការគាំទ្រ និងសេវាកម្មឯកទេសសម្រាប់សិស្សដែលមានតម្រូវការខ្ពស់នៅក្នុងថ្នាក់ទាំងនោះផងដែរ ដរាបណាសាលាអាចគោរពតាមសេចក្តីតម្រូវនៃការរក្សាគំលាតរាងកាយ ការគ្រប់

គ្រងការឆ្លងជំងឺ និងការបែងចែងជាក្រុម។

- សេវាកម្មឯកទេសអាចរាប់បញ្ចូល តែមិនដាក់កម្រិតចំពោះសេវាកម្មព្យាបាលការងារ សេវាកម្មពាក្យសម្តី និងភាសា សេវាកម្មវេជ្ជសាស្ត្រផ្សេងៗទៀត សេវាកម្មអាកប្បកិរិយា សេវាកម្មគាំទ្រការអប់រំជាផ្នែកនៃយុទ្ធសាស្ត្រអន្តរាគមន៍មានគោលដៅ ឬការវាយតម្លៃ ដូចជាការវាយតម្លៃដែលទាក់ទងនឹងស្ថានភាពអ្នកសិក្សាភាសាអង់គ្លេស ផែនការអប់រំលក្ខណៈបុគ្គល និងការវាយតម្លៃដែលបានតម្រូវផ្សេងៗទៀត។
- កុមារមិនត្រូវចូលរួមក្នុងក្រុមច្រើនជាងមួយឡើយ។ សិស្សដែលជាផ្នែកនៃក្រុម អាចចាកចេញពីក្រុមដើម្បីទទួលសេវាកម្មបន្ថែម។ ទោះជាយ៉ាងណាក៏ដោយ សេវាកម្មបន្ថែមនានាត្រូវតែផ្តល់ឲ្យមួយទល់មួយដោយអ្នកឯកទេសសមស្របនៅក្នុងទីកន្លែងដែលមានសុវត្ថិភាព ដែលដាច់ដោយឡែកពីមនុស្សដទៃទៀត។
- សាលាត្រូវតែយល់ព្រមសហការជាមួយ DPH ទាក់ទងនឹងការត្រួតពិនិត្យ ការតាមដាន និងការរក្សាទុកឯកសារដែលនឹងចាំបាច់ដើម្បីធ្វើការពិនិត្យសុខភាពយ៉ាងយកចិត្តទុកដាក់ ពាក់ព័ន្ធនឹងរយៈពេលដំបូងនៃការពង្រីកនេះ។
- ទៅតាមកម្រិតដែលសមស្របតាមតម្រូវការឯកទេសរបស់សិស្សនៅក្នុងក្រុម ការប្រើទីធ្លាខាងក្រៅអគារយ៉ាងតិច 50% នៃថ្ងៃសិក្សា គឺត្រូវបានណែនាំយ៉ាងមុតមាំ។
- LEAs និងសាលារៀនដែលជ្រើសរើសអនុវត្តសេវាកម្មនៅនឹងកន្លែងទាំងនេះសម្រាប់សិស្សដែលមានតម្រូវការឯកទេស ត្រូវតែជូនដំណឹងដល់នាយកដ្ឋានសុខភាពសាធារណៈរបស់ខោនធី Los Angeles អំពីផែនការរបស់ខ្លួនមុននឹងចាប់ផ្តើមសេវាកម្ម។ បើសិនជាសាលារៀនបានទទួលការអនុម័តសម្រាប់ការលើកលែងដើម្បីបើកឡើងវិញសម្រាប់សិស្សនៅក្នុងថ្នាក់ទី TK – 2 រួចហើយ សាលានៅតែត្រូវបានតម្រូវឲ្យធ្វើការជូនដំណឹងដើម្បីផ្តល់សេវាកម្មដល់សិស្សដែលមានតម្រូវការពិសេស បើសិនជាសាលាមានបំណងនាំសិស្សត្រឡប់មកកាន់បរិវេណសាលាវិញបន្ថែមលើសិស្សនៅក្នុងថ្នាក់ទី TK – 2 ទាំងនោះ។ សំណុំបែបបទរាយការណ៍អាចរកបាននៅ សំណុំបែបបទជូនដំណឹងអំពីការបង្រៀនក្រុមតូច (Small Group Instruction Notification Form)។
- ព័ត៌មានបន្ថែមពីរដ្ឋទាក់ទងនឹងសេវាកម្មឯកទេសអាចរកបាននៅ ការគាំទ្រនិងសេវាកម្មឯកទេស (Specialized Support and Services)។

- **ការបង្រៀននៅនឹងកន្លែងសម្រាប់កុមារក្នុងថ្នាក់ TK-2 ដោយសាលារៀនដែលបានទទួលការលើកលែងពីនាយកដ្ឋានសុខភាពសាធារណៈសម្រាប់ការអប់រំដោយផ្ទាល់។**
  - គ្មានសាលារៀនណាមួយអាចនាំសិស្សក្នុងថ្នាក់ទី TK-2 មកកាន់បរិវេណសាលាសម្រាប់ការបង្រៀនក្នុងថ្នាក់ទូទៅ មុនការលើកលែងត្រូវបានអនុម័តឡើយ។
  - សេចក្តីណែនាំពេញលេញ និងទម្រង់ពាក្យសុំការលើកលែង គឺមាននៅទីនេះ។
- **សិស្សអាចមកកាន់បរិវេណសាលាសម្រាប់ការប្រឡងចូលមហាវិទ្យាល័យដែលមានការគ្រប់គ្រងដូចជាការប្រឡង PSAT, ACT និង SAT។**
  - ការប្រឡងចូលមហាវិទ្យាល័យ រួមមានការប្រឡង PSAT, ACT និង SAT អាចត្រូវបានធ្វើឡើងនៅសាលារៀនបាន ដរាបណាសិស្សត្រូវបានបែងចែកជាក្រុមត្រឹមត្រូវសម្រាប់រយៈពេលនៃការប្រឡងទាំងមូល (មិនឲ្យមានសិស្សលើសពី 12 នាក់នៅក្នុងបន្ទប់ប្រឡងនីមួយៗដោយមានគំលាតយ៉ាងតិចបំផុត 6 ហ្វីតរវាងសិស្ស ក៏ដូចជារវាងសិស្ស និងគ្រូ។
  - សិស្សនិងបុគ្គលិកទាំងអស់គឺត្រូវពាក់របាំងមុខនៅគ្រប់ពេលវេលានៅលើបរិវេណសាលា បទបញ្ជាគ្រប់គ្រងការឆ្លងជំងឺត្រូវបានអនុវត្ត។
  - មិនមានការប្រមូលផ្តុំនៅពេលមកដល់ និងពេលចាកចេញ ឬក្នុងអំឡុងពេលសម្រាកពីការប្រឡងឡើយ។

វិធានការណ៍ទាំងអស់ដើម្បីធានាបាននូវសុវត្ថិភាពរបស់បុគ្គលិកនិងសិស្សនៅក្នុងពិធីការនេះសម្រាប់ការបើកសាលារៀន TK-12 ឡើងវិញ និងនៅក្នុងពិធីការដែលពាក់ព័ន្ធសម្រាប់ការគ្រប់គ្រងការប៉ះពាល់នៅសាលារៀន K-12 ត្រូវតែអនុវត្ត និងអាចអនុវត្តបានចំពោះបុគ្គលិកនៅនឹងកន្លែងទាំងអស់ ដោយរាប់បញ្ចូលទាំងបុគ្គលិកដែលផ្តល់សេវាកម្មឯកទេស។ កឋាខណ្ឌខាងក្រោមលើកឡើងពីយុទ្ធសាស្ត្រសុវត្ថិភាពដែលជាក់លាក់សម្រាប់បរិស្ថានសាលារៀន។ ធនធានបន្ថែមសម្រាប់សាលារៀន K-12 អាចរកបាននៅក្នុង K-12 School COVID-19 Toolkit។

## ការបែងចែកជាក្រុម

សម្រាប់កម្មវិធីនៅនឹងកន្លែងទាំងបួនប្រភេទនេះ គេត្រូវតែរៀបចំសិស្ស និងបន្តសកម្មភាពក្នុងថ្ងៃនោះជាក្រុមដែលបានកំណត់ថាជាក្រុមដែលមានស្ថិរភាពដែលមានកុមារ ឬយុវជនមិនលើសពី 12 នាក់ និងមនុស្សធំគ្រប់គ្រងមិនលើសពីរនាក់នៅក្នុងបរិយាកាសដែលមានការគ្រប់គ្រង ដែលមនុស្សធំគ្រប់គ្រង និងកុមារស្ថិតនៅជាមួយគ្នាសម្រាប់គ្រប់សកម្មភាពទាំងអស់ (ឧ. ម្ហូបអាហារ ការលំហែ ។ល។) និងជៀសវាងការប៉ះពាល់ជាមួយមនុស្សក្រៅពីក្រុមរបស់ខ្លួននៅក្នុងទីកន្លែង។

- ចូរកត់សម្គាល់ថា បើសិនជាក្រុមសិស្សមានកុមារតិចជាង 12 នាក់ ឬបើសិនជាកុមារឈប់ចូលរួមក្រុមដែលបានពេញកាលពីមុន កុមារផ្សេងទៀតដែលមិនទាន់បានបែងចែកក្រុម អាចត្រូវបានបន្ថែមទៅក្នុងក្រុមដើម្បីឈានដល់ចំនួន 12 ជាអតិបរមាបាន ក្នុងករណីដែលកុមារទាំងអស់ បន្ទាប់ពីចាត់តាំងរួច បន្តស្ថិតនៅក្នុងក្រុមដដែលនៅគ្រប់ពេលវេលា។
- បើសិនជាកុមារមួយចំនួន ត្រូវបានចាត់តាំងសម្រាប់ក្រុមដែលមានស្ថិរភាព ប៉ុន្តែចូលរួមតែក្រៅម៉ោង ពួកគេត្រូវតែរាប់ជាសមាជិកពេញលេញជៀបនឹងចំនួន 12 នាក់ជាអតិបរមា។ សមាជិកក្រៅម៉ោងមិនអាច "ចែករំលែក" កន្លែងរបស់ខ្លួនជាមួយសិស្សក្រៅម៉ោងផ្សេងទៀតបានឡើយ។  គេមិនអាចបន្ថែមកុមារផ្សេងទៀតដើម្បីឈានដល់ចំនួនអ្នកចូលរួម 12 នាក់ជាអតិបរមានៅគ្រប់ពេលវេលាបានឡើយ។
- ជំនួយការដែលត្រូវបានចាត់តាំងសម្រាប់កុមារម្នាក់ៗ មិនចាំបាច់ត្រូវរាប់ជាមនុស្សធំគ្រប់គ្រងឡើយ។ ទោះជាយ៉ាងណាក៏ដោយ គេត្រូវតែរាប់ពួកគេជៀបជាមួយមនុស្ស 14 នាក់ជាអតិបរមាដែលអាចត្រូវបានដាក់នៅក្នុងក្រុមមួយ។ ព័ត៌មានលម្អិតបន្ថែមសំខាន់ៗសម្រាប់ការអនុវត្តក្រុម គឺមានពីនាយកដ្ឋានសុខភាពសាធារណៈ CA នៅការណែនាំសម្រាប់ក្រុមតូចៗ (Guidance for Small Cohorts)។

### ចំនួនសិស្សនៅលើបរិវេណសាលាដែលបានកំណត់

ខណៈដែលទីភ្នាក់ងារអប់រំក្នុងតំបន់ (LEAs) ឬសាលារៀនអាចនឹងរៀបចំឲ្យមានច្រើនក្រុមបំផុតតាមដែលអាចធ្វើបាន ដើម្បីបំពេញតម្រូវការសិស្សសម្រាប់សេវាកម្មឯកទេស ចំនួនសិស្សសរុបនៅអគារសាលាមិនអាចលើសពី 25% នៃចំនួនសិស្សសរុបក្នុងពេលណាមួយសម្រាប់គោលបំណងជាក់លាក់នេះបានឡើយ។ ដែនកំណត់ 25% នេះមិនអនុវត្តទៅលើកុមារគ្រប់អាយុចូលរៀននៅលើបរិវេណសាលាដែលកំពុងទទួលការថែទាំពេលថ្ងៃ ខណៈចូលរួមក្នុងសកម្មភាពសិក្សាពីចម្ងាយនោះទេ ហើយក៏មិនអនុវត្តទៅលើសិស្សនៅក្នុងថ្នាក់ TK-2 ដែលត្រឡប់ចូលរៀនវិញបន្ទាប់ពីទទួលបានការលើកលែងរបស់សាលារៀនដែរ។ សាលារៀនដែលបានទទួលការលើកលែងដើម្បីនាំសិស្សនៅក្នុងថ្នាក់ទី TK – 2 ត្រឡប់មកវិញ អាចនាំសិស្សបន្ថែមមកកាន់បរិវេណសាលាសម្រាប់សេវាកម្មឯកទេសនៅក្នុងថ្នាក់ខ្ពស់ជាងថ្នាក់ទី 2 បានប៉ុន្តែមិនមែនរហូតដល់ 25% នៃចំនួនសិស្សចុះឈ្មោះសរុបឡើយ។ បើសិនជាសាលាដែលបានទទួលការលើកលែងសម្រាប់ថ្នាក់ទី TK – 2 សាលាអាចនាំសិស្សបន្ថែមមកកាន់បរិវេណសាលាសម្រាប់សេវាកម្ម និងការវាយតម្លៃរហូតដល់ 25% នៃចំនួនសិស្សសរុបនៅក្នុងថ្នាក់ទី 3 និងថ្នាក់ខ្ពស់ជាងនេះ ដរាបណាសាលារៀនអាចគោរពតាមសេចក្តីបង្គាប់នៃការរក្សាគំលាត ការគ្រប់គ្រងការឆ្លងជំងឺ និងការបែងចែកជាក្រុម។

### មនុស្សធំគ្រប់គ្រង

មនុស្សធំគ្រប់គ្រង គឺជាមនុស្សធំដែលត្រូវបានចាត់តាំងសម្រាប់កុមារ ឬយុវជនមួយក្រុម ដែលមិនមានការប្រាស្រ័យទាក់ទង ផ្នែករាងកាយជាមួយក្រុមផ្សេងទៀត។ មនុស្សធំគ្រប់គ្រង អាចជាបុគ្គលិកថែទាំកុមារ បុគ្គលិកសាលាដែលមានវិញ្ញាបនបត្រ បញ្ជាក់ ឬបានចាត់ជាក្រុម អ្នកស្ម័គ្រចិត្ត ឪពុកម្តាយឬ អ្នកផ្តល់ការថែទាំដែលចូលរួម ឬមនុស្សធំគ្រប់គ្រងដែលបានចាត់តាំងផ្សេងទៀត។ ជំនួយការដែលមានវត្តមានដើម្បីផ្តល់ជំនួយដល់កុមារម្នាក់ៗ គួរត្រូវបានរាប់ជាសមាជិកក្រុម ប៉ុន្តែមិនមែនជាមនុស្សធំគ្រប់គ្រងឡើយ។ មនុស្សធំគ្រប់គ្រងម្នាក់អាចត្រូវបានចាត់តាំងសម្រាប់ក្រុមដែលមានស្ថិរភាព 2 ខុសៗគ្នាបាន បើសិនជាពួកគេផ្តល់សេវាកម្ម/ការគាំទ្រឯកទេសដែលមនុស្សធំគ្រប់គ្រងផ្សេងទៀតមិនអាចផ្តល់ជូនបាន។

### បរិស្ថានដែលបានគ្រប់គ្រង

បរិយាកាសថែទាំដែលមានការគ្រប់គ្រង គឺជាបរិយាកាសដែលកុមារ ឬយុវជនច្រើននាក់មកពីគ្រួសារច្រើន ត្រូវបានគ្រប់គ្រងក្នុងពេលតែមួយដោយមនុស្សធំម្នាក់។ នេះរាប់បញ្ចូល តែមិនដាក់កម្រិតចំពោះទីកន្លែងថែទាំកុមារដែល

មានអាជ្ញាប័ណ្ណ កម្មវិធីថែទាំកុមារលើកលែងដែលមានអាជ្ញាប័ណ្ណកម្មវិធីដែលមានការគ្រប់គ្រងនៅលើទីតាំងសាលារៀន ខណៈដែលសាលារៀនមិនមានការបង្រៀន ឬកំពុងផ្តល់កម្មវិធីសិក្សាក្នុងទម្រង់សិក្សាពីចម្ងាយ ឬនៅកន្លែងដែលសេវាអប់រំមួយចំនួនកំពុងត្រូវបានផ្តល់ឲ្យអនុក្រុមសិស្ស ដូចបានកំណត់ដោយទីភ្នាក់ងារអប់រំក្នុងតំបន់នៅតាមសាលារៀន។

**បញ្ជីត្រួតពិនិត្យការបើកឡើងវិញថ្នាក់ TK ដល់ថ្នាក់ទី 12**

**ឈ្មោះស្ថាប័ន៖**

**អាសយដ្ឋាន៖**

**ចំនួនមនុស្សអតិបរមា តាមច្បាប់អគ្គិភ័យ៖**

**ប្រហាក់ប្រហែលទំហំទីធ្លាគិតសរុបជាហ្វីតការ៉េ ដែលបើកដល់សម្រាប់បុគ្គលិកសាលា និង/ឬសិស្ស៖**

---

**ចំនួនសរុបប៉ាន់ប្រមាណនៃមន្ត្រីរដ្ឋបាល គ្រូបង្រៀន និងបុគ្គលិកផ្សេងទៀតដែលនឹងត្រឡប់មកជំនួយបន្តសេវាកម្មដោយផ្ទាល់ដែលបានអនុញ្ញាតទាំងអស់សម្រាប់សិស្ស៖**

---

**ចំនួនសរុបប៉ាន់ប្រមាណនៃសិស្សដែលនឹងត្រឡប់ចូលក្នុងមួយថ្នាក់ (បើគ្មាន សូមសរសេរលេខ 0)៖**

**TK:** _______ **K:** ________ **1:** ________ **2:** ________ **3:** ________ **4:** ________ **5:** ______

**6:** _______ **7:** ________ **8:** ________ **9:** ________ **10:** ________ **11:** ________ **12:** ______

**កំណត់សម្គាល់៖** ពាក្យ "និយោជិក" និង "បុគ្គលិក" ត្រូវបានប្រើនៅក្នុងពិធីការទាំងនេះដើម្បីសំដៅលើបុគ្គលដែលធ្វើការនៅក្នុងសាលារៀនក្នុងផ្នែកណាមួយដែលពាក់ព័ន្ធនឹងការបង្រៀន ការបង្ហាត់ ជំនួយសិស្ស ផ្តល់ការព្យាបាលឬជំនួយផ្ទាល់ខ្លួនដល់សិស្សម្នាក់ៗ ការសម្អាតនិងថែទាំអគារ រដ្ឋបាល ឬសកម្មភាពផ្សេងៗទៀតដែលចាំបាច់ដើម្បីឲ្យសាលារៀនដំណើរការបាន។ "និយោជិក" ឬ "បុគ្គលិក" អាចរាប់បញ្ចូលបុគ្គលដែល៖ ទទួលប្រាក់ឈ្នួលដោយផ្ទាល់ពីប្រព័ន្ធសាលារៀនដែលពាក់ព័ន្ធ ទទួលប្រាក់ឈ្នួលពីស្ថាប័នដែលដើរតួជាអ្នកម៉ៅការជាមួយសាលា ទទួលប្រាក់ឈ្នួលពីស្ថាប័នខាងក្រៅដែលសហការជាមួយសាលារៀនដើម្បីបម្រើសេវាដល់សិស្ស ទទួលប្រាក់ឈ្នួលពីភាគីទីបីដើម្បីផ្តល់សេវាកម្មដល់សិស្សម្នាក់ៗ ឬជាអ្នកស្ម័គ្រចិត្តដែលគ្មានប្រាក់ឈ្នួលធ្វើការក្រោមការណែនាំរបស់សាលាដើម្បីបំពេញមុខងារសំខាន់ៗ។ ពាក្យ "ឪពុកម្តាយ" ត្រូវបានប្រើនៅក្នុងពិធីការទាំងនេះដើម្បីសំដៅលើបុគ្គលទាំងឡាយណាដែលដើរតួជាអ្នកផ្តល់ការថែទាំ ឬអាណាព្យាបាលសិស្ស។

## A. គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារបុគ្គលិក ("និយោជិក") និងសិស្ស (គូសធីកទាំងអស់ដែលអនុវត្ត)

សាលារៀនមានផែនការទប់ស្កាត់ ឆ្លើយតបនិងគ្រប់គ្រងជំងឺ COVID-19 ដែលពិពណ៌នាអំពីវិធីសាស្ត្រដ៏ទូលំទូលាយរបស់សាលាដើម្បីទប់ស្កាត់ និងគ្រប់គ្រងការរីករាលដាលនៃជំងឺ COVID-19 នៅក្នុងអគារសាលារៀន។ ផែនការនេះរាប់បញ្ចូលតែមិនកំណត់លើចំណុចដូចខាងក្រោម៖

- ❑ ក្រុមការងារអនុវត្តច្បាប់សម្រាប់ជំងឺ COVID-19 ដែលបានចាត់តាំង ដែលទទួលខុសត្រូវលើការបង្កើត និងអនុវត្តពិធីការសុវត្ថិភាពជំងឺ COVID-19 ទាំងអស់ និងប្រាកដថាបុគ្គលិកនិងសិស្សទទួលបានការអប់រំអំពីជំងឺ COVID-19។ សមាជិកម្នាក់នៃក្រុមការងារនេះ ត្រូវបានចាត់តាំងជាអ្នកទាក់ទងជាមួយ DPH ក្នុងករណីដែលមានការផ្ទុះជំងឺនៅក្នុងអគារសាលា។

- ❑ ផែនការ ឬពិធីការសម្រាប់ជំហានដែលនឹងត្រូវអនុវត្តភ្លាមៗបន្ទាប់ពីមានការជូនដំណឹងដោយបុគ្គលិក

សាលាថាសមាជិកណាម្នាក់នៃសហគមន៍សាលារៀន (មន្ត្រី បុគ្គលិក សិស្ស ឬភ្ញៀវ) ធ្វើតេស្តវិជ្ជមាន ឬមានរោគសញ្ញាដូចគ្នានឹងជំងឺ COVID-19។ ផែនការដោះស្រាយ៖

- ការបំបែកករណីភ្លាមៗពីសហគមន៍សាលារៀន ដើម្បីឲ្យដាក់ខ្លួនឲ្យនៅដាច់ដោយឡែកនៅផ្ទះ បើសិនជាការជូនដំណឹងកើតឡើងខណៈដែលករណីស្ថិតនៅទីកន្លែង។ ផែនការត្រូវតែអនុញ្ញាតឲ្យមានការដាក់ខ្លួនករណីឲ្យនៅដាច់ដោយឡែកជាបណ្តោះអាសន្ន នៅនឹងកន្លែង បើសិនជាចាំបាច់ត្រូវមានការរៀបចំសម្រាប់ឲ្យបុគ្គលនោះត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ។
- សន្លឹកការពិត ឬឯកសារព័ត៌មានផ្សេងៗទៀតដែលត្រូវប្រគល់ឲ្យករណី (ឬសមាជិកគ្រួសារដែលសមស្រប បើករណីគឺជាកុមារ) ដែលរៀបរាប់អំពីបទប្បញ្ញត្តិគ្រប់គ្រងលើការដាក់ខ្លួនឲ្យនៅដាច់ដោយឡែក និងតំណទៅកាន់គេហទំព័រដែលមានព័ត៌មានបន្ថែម។

❑ ផែនការ ឬពិធីការដើម្បីចាប់ផ្តើមផែនការគ្រប់គ្រងការរាលដាលនៅសាលារៀន ដែលស្របទៅតាមការណែនាំរបស់ DPH ដែលគូសបញ្ជាក់ពីនីតិវិធីសម្រាប់៖
- ការដាក់ករណីមួយ ឬច្រើនឲ្យនៅដាច់ដោយឡែក
- ការកំណត់អត្តសញ្ញាណបុគ្គលដែលបានប៉ះពាល់ជាមួយករណីនៅសាលារៀន
- ការដាក់ឲ្យនៅដាច់ពីគេភ្លាមៗសម្រាប់បុគ្គលិក និង/ឬសិស្សដែលបានប៉ះពាល់ និង
- ការធានាពីការទទួលការធ្វើតេស្តសម្រាប់បុគ្គលដែលបានប៉ះពាល់ទាំងអស់នៅក្នុងសាលារៀនជាមូលដ្ឋានសម្រាប់វិធានការណ៍គ្រប់គ្រងបន្តទៀត។

❑ ការជូនដំណឹងដល់ DPH ពីករណីជំងឺ COVID-19 ដែលបានបញ្ជាក់ទាំងអស់ ក្នុងចំណោមបុគ្គលិក និងកុមារដែលបានស្ថិតនៅសាលារៀននៅចំណុចណាមួយក្នុងរយៈពេល 14 ថ្ងៃចុងក្រោយមុនពេលធ្លាក់ខ្លួនឈឺ។ កាលបរិច្ឆេទចាប់ផ្តើមកើតជំងឺ គឺជាកាលបរិច្ឆេទធ្វើតេស្តជំងឺ COVID-19 ឬកាលបរិច្ឆេទចាប់ផ្តើមចេញរោគសញ្ញារបស់មនុស្សឈឺ មួយណាក៏ដោយដែលកើតមុន។ ការរាយការណ៍ពីករណី គួរត្រូវបានធ្វើឡើងតាមអ៊ីមែលដោយបំពេញ តារាងសង្ខេបព័ត៌មានទំនាក់ទំនងករណីនិងអ្នកប៉ះពាល់ជំងឺ COVID-19 សម្រាប់វិស័យអប់រំ និងផ្ញើវាទៅកាន់ ACDC-Education@ph.lacounty.gov ក្នុងរយៈពេល 1 ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីទទួលដំណឹងអំពីករណី។ ផែនការដើម្បីរាយការណ៍ជាបន្ទាន់ពីចង្កោមករណី (3 ករណី ឬច្រើនជាងនេះក្នុងអំឡុងពេល 14 ថ្ងៃ) ដល់នាយកដ្ឋានសុខភាពសាធារណៈតាមរយៈអ៊ីមែលនៅ ACDC-Education@ph.lacounty.gov ឬដោយទូរស័ព្ទទៅលេខ (888) 397-3993 ឬ (213) 240-7821។ នាយកដ្ឋានសុខភាពសាធារណៈ នឹងធ្វើការជាមួយសាលារៀនដើម្បីកំណត់ថាតើចង្កោមនេះគឺជាការផ្ទុះជំងឺដែលតម្រូវឲ្យមានការឆ្លើយតបនឹងការផ្ទុះជំងឺពីផ្នែកសុខភាពសាធារណៈឬទេ។

❑ សាលារៀនដែលត្រូវបានកំណត់ដោយនាយកដ្ឋានសុខភាពសាធារណៈថាមានការផ្ទុះជំងឺ (3 ករណីឬច្រើនជាងនេះក្នុងរយៈពេល 14 ថ្ងៃ) ត្រូវតែបិទទ្វាររយៈពេល 14 ថ្ងៃ។ លក្ខខណ្ឌតម្រូវឲ្យបិទនេះ អនុវត្តចំពោះកម្មវិធីសម្រាប់កុមារដែលកំពុងធ្វើប្រតិបត្តិការនៅលើអគារសាលាមុនពេល អំឡុងពេល ឬបន្ទាប់ពីម៉ោងសិក្សាធម្មតា។ វារាប់បញ្ចូលតែមិនដាក់កម្រិតត្រឹម ការថែទាំនៅពេលថ្ងៃសម្រាប់កុមារគ្រប់អាយុចូលរៀន កន្លែងបោះតង់ និងកីឡាយុវជន។

❑ ផែនការត្រៀមបម្រុងសម្រាប់ការបិទទាំងស្រុង ឬដោយផ្នែកនៃប្រតិបត្តិការសាលារៀនដោយផ្ទាល់ បើសិនជាចាំបាច់ដោយផ្អែកលើការផ្ទុះជំងឺនៅក្នុងសាលារៀនឬសហគមន៍។

❑ ផែនការឬពិធីការដើម្បីដាក់បញ្ចូលការធ្វើតេស្តត្រួតពិនិត្យទៅក្នុងប្រតិបត្តិការសាលារៀនធម្មតាសម្រាប់បុគ្គលិកសាលារៀនទាំងអស់។

- ផែនការត្រូវតែពិពណ៌នាអំពីយុទ្ធសាស្ត្រដើម្បីធានាបាននូវការទទួលបានការធ្វើតេស្ត តាមកាលកំណត់សម្រាប់បុគ្គលិកសាលារៀនទាំងអស់ ដែលនឹងត្រូវអនុវត្តនៅពេលមានការណែនាំពីនាយកដ្ឋានសុខភាពសាធារណៈទៅលើនិន្នាការជំងឺតាមមូលដ្ឋាន និង/ឬបន្ទាប់ពីការដោះស្រាយការផ្ទុះជំងឺនៅសាលារៀន។

- ផែនការត្រូវតែផ្តល់លទ្ធផលតេស្តតាមដានទាំងអស់ ដែលនឹងត្រូវបានរាយការណ៍ទៅកាន់នាយកដ្ឋានសុខភាពសាធារណៈ

❑ បុគ្គលិកងាយរងគ្រោះ (អ្នកដែលមានអាយុលើស 65 ឆ្នាំ និងអ្នកដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃដែលអាចធ្វើឲ្យពួកគេមានហានិភ័យ (risk) ខ្ពស់បើឆ្លងជំងឺ) ត្រូវបានកំណត់ឲ្យធ្វើការងារដែលអាចធ្វើបានពីផ្ទះនៅគ្រប់ពេលដែលអាចធ្វើទៅបាន។ បុគ្គលិកនៅក្នុងចំណាត់ថ្នាក់នេះ គួរពិភាក្សាពីក្តីកង្វល់នានាជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់ខ្លួន ឬសេវាកម្មសុខភាពការងារដើម្បីធ្វើការសម្រេចចិត្តសមស្របអំពី

ការត្រឡប់ទៅធ្វើការវិញ។

- ❑ ដំណើរការការងារត្រូវបានកែទម្រង់ឡើងវិញទៅតាមកម្រិតដែលត្រូវគ្នាជាមួយសេចក្តីតម្រូវការសិក្សា និងតម្រូវការសិស្ស ដើម្បីបង្កើនឱកាសឲ្យបុគ្គលិកធ្វើការពីផ្ទះ។
- ❑ ដោយអនុលោមតាមច្បាប់ស្តីពីប្រាក់ឈ្នួលនិងម៉ោងការងារ និងបទបញ្ជាសាលា កាលវិភាគធ្វើការផ្សេងគ្នាឆ្លាស់គ្នា ឬប្តូរវេនគ្នាត្រូវបានបង្កើតឡើងដើម្បីបង្កើនការរក្សាគំលាតរាងកាយនៅពេលដែលអាចធ្វើបាន។
- ❑ បុគ្គលិកទាំងអស់ត្រូវបានប្រាប់កុំឲ្យមកធ្វើការបើសិនជាឈឺ ឬបើសិនជាពួកគេបានប៉ះពាល់ជាមួយបុគ្គលដែលមានជំងឺ COVID-19។ បុគ្គលិកសាលាបានផ្តល់ព័ត៌មានដល់បុគ្គលិកដែលទាក់ទងនឹង អត្ថប្រយោជន៍នៃការសុំច្បាប់ឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬដោយរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងសិទ្ធិរបស់អ្នកដើម្បីទទួលបានការឈប់សម្រាកឈឺ មានប្រាក់ឈ្នួលដែលបានធានាដោយ ច្បាប់ស្តីពីការឆ្លើយតបនឹងមេរោគកូរ៉ូណាដោយយកគ្រួសារជាអាទិភាព (Families First Coronavirus Response Act)។
- ❑ ការប្រើប្រាស់អគារសាលារៀនក្នុងគោលបំណងក្រៅពីការសិក្សា (ការប្រជុំឬព្រឹត្តិការណ៍សហគមន៍ ការពិនិត្យគ្លីនិកនៅនឹងកន្លែងដោយបុគ្គលដែលមិនមែនជាសិស្ស ឬបុគ្គលិក ។ល។) មិនត្រូវបានអនុញ្ញាតឡើយ។
- ❑ ការត្រួតពិនិត្យបុគ្គលិក ត្រូវបានធ្វើឡើងមុនពេលដែលបុគ្គលិកអាចចូលក្នុងកន្លែងធ្វើការ។ ការត្រួតពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យទាក់ទងនឹងការក្អក ការដកដង្ហើមខ្លីៗ ការពិបាកដកដង្ហើម និងគ្រុនក្តៅឬគ្រុនញាក់ ហើយប្រសិនបើបុគ្គលិកបានប៉ះពាល់ជាមួយមនុស្សដែលត្រូវបានគេដឹងថាបានឆ្លងមេរោគ COVID-19 នៅក្នុងរយៈពេល 14 ថ្ងៃចុងក្រោយ។

- ❑ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានពីចម្ងាយ ឬដោយផ្ទាល់នៅពេលបុគ្គលិកនោះមកដល់។ ការត្រួតពិនិត្យសីតុណ្ហភាពក៏គួរតែត្រូវបានធ្វើនៅកន្លែងធ្វើការប្រសិនបើអាច។

- ❑ នរណាម្នាក់ដែលចូលក្នុងបរិវេណឬទ្រព្យសម្បត្តិសាលារៀន (រថយន្តក្រុងរបស់សាលា ក៏ដូចជាអគារ និងទីធ្លាសាលា) ដែលប៉ះពាល់ជាមួយអ្នកដទៃ (សិស្ស ឪពុកម្តាយ ឬបុគ្គលិកផ្សេងទៀត) ត្រូវបានតម្រូវឲ្យពាក់ក្រណាត់បាំងមុខ។
  - ○ បុគ្គលិកណាដែលមានការប៉ះពាល់ជាមួយអ្នកដទៃត្រូវបានផ្តល់ជូន ដោយមិនគិតថ្លៃនូវរបាំងមុខសមរម្យដែលគ្របលើច្រមុះនិងមាត់។ របាំងមុខគឺត្រូវពាក់ដោយបុគ្គលិកនៅគ្រប់ពេលវេលាក្នុងថ្ងៃធ្វើការនៅពេលដែលប៉ះពាល់ឬទំនងជាប៉ះពាល់ជាមួយអ្នកដទៃ។ បុគ្គលិកណាដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ពួកគេថា ពួកគេមិនគួរពាក់របាំងមុខ ក៏គួរពាក់សន្ទះការពារមុខដោយប្រើក្រវ៉ាត់នៅគែមខាងក្រោមឲ្យត្រូវតាមសេចក្តីណែនាំរបស់រដ្ឋ ដរាបណាល័ក្ខខ័ណ្ឌរបស់ពួកគេអនុញ្ញាត។ យកល្អគួរប្រើក្រណាត់ហ៊ុមខាងក្រោមដែលមានទម្រង់រឹតតឹងខាងក្រោមចង្កា។ ម៉ាស់ដែលមានវ៉ាល់មួយផ្លូវមិនគួរប្រើទេ។
  - ○ បុគ្គលិកមិនចាំបាច់ពាក់របាំងមុខពេលនៅម្នាក់ឯងក្នុងការិយាល័យឯកជន ឬបន្ទប់តូចដែលមានជញ្ជាំងរឹងលើសពីកម្ពស់របស់និយោជិកនៅពេលឈរនោះឡើយ។
  - ○ ដោយអនុលោមតាមសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលដើម្បីគ្រប់គ្រងជំងឺ COVID-19៖ ការឆ្លើយតបនឹងការកើនឡើងខ្លាំងលំដាប់ថ្នាក់ទី 1 បានចេញនៅថ្ងៃទី 28 ខែវិច្ឆិកាឆ្នាំ 2020 បុគ្គលិកទាំងអស់ត្រូវតែពាក់របាំងមុខនៅគ្រប់ពេលវេលា លើកលែងតែពេលធ្វើការម្នាក់ឯងនៅក្នុងការិយាល័យឯកជនដោយបិទទ្វារជិត ឬនៅពេលបរិភោគ ឬផឹក។ ករណីលើកលែងដែលមានសម្រាប់បុគ្គលិកដែលធ្វើការនៅក្នុងបន្ទប់តូចដោយមានរបាំងខ័ណ្ឌរឹងមាំហួសពីកម្ពស់របស់បុគ្គលិកខណៈពេលឈរត្រូវបានបដិសេធចោល។
  - ○ ម៉ាស់កម្រិតវេជ្ជសាស្ត្រត្រូវបានផ្តល់ឲ្យបុគ្គលិកទាំងឡាយណាដែលថែទាំកុមារឈឺ ឬអ្នកដែលប៉ះពាល់ជាមួយកុមារនានាដែលមានបញ្ហាសុខភាពដែលរារាំងកុមារពីការប្រើប្រាស់ក្រណាត់បាំងមុខ។
  - ○ យុទ្ធសាស្ត្រការពារផ្សេងទៀតអាចត្រូវបានអនុវត្តដើម្បីសម្រួលដល់សិស្សដែលស្ថិតនៅក្នុងការអប់រំមានលក្ខណៈបុគ្គល ឬផែនការ 504 និងអ្នកដែលមិនអាចប្រើ ឬទ្រាំនឹងក្រណាត់បាំងមុខបាន។

- ❑ បុគ្គលិកត្រូវបានណែនាំឲ្យបោកគក់ ឬផ្លាស់ប្តូររបាំងមុខរបស់ខ្លួនជារៀងរាល់ថ្ងៃ។ ឪពុកម្តាយត្រូវបានណែនាំឲ្យធានាបានថាកុមារមានរបាំងមុខដែលស្អាត។

- ❑ ស្ថានីយការងារ ឬទីកន្លែងបុគ្គលិកទាំងអស់ដែលត្រូវបានប្រើដោយបុគ្គលិកធ្វើការ ជាផ្នែកមួយនៃក្រុមអនុញ្ញាតឲ្យមានគំលាតពីគ្នាយ៉ាងតិច 6 ហ្វីត។ គ្រឿងសង្ហារឹមក្នុងបន្ទប់រៀនត្រូវបានរៀបចំដើម្បីអនុញ្ញាតឲ្យមានគំលាតយ៉ាងតិច 6 ហ្វីតរវាងគ្រូ និងសិស្សដែលនៅជិតបំផុត។

- ❑ ដើម្បីធ្វើឲ្យប្រាកដថាម៉ាស់ត្រូវបានពាក់យ៉ាងខ្ជាប់ខ្ជួននិងត្រឹមត្រូវ បុគ្គលិកត្រូវបានរារាំងមិនឲ្យបរិភោគ ឬផឹក លើកលែងតែក្នុងអំឡុងពេលការសម្រាករបស់ពួកគេ នៅពេលដែលពួកគេអាចដោះម៉ាស់របស់ខ្លួន និងរក្សាគំលាតរាងកាយពីអ្នកដទៃបានដោយសុវត្ថិភាព។ នៅគ្រប់ពេលវេលាទាំងអស់នៅពេលបរិភោគ ឬផឹក បុគ្គលិកត្រូវតែរក្សាគំលាតយ៉ាងតិច 6 ហ្វីតពីអ្នកដទៃ។ នៅពេលបរិភោគ ឬផឹក វាជាការប្រសើរ ដែលត្រូវធ្វើដូច្នោះនៅខាងក្រៅអគារ និងឆ្ងាយពីអ្នកដទៃ ដោយរាប់បញ្ចូលទាំងភ្ញៀវ។ ការបរិភោគ ឬការផឹកនៅបន្ទប់តូច ឬស្ថានីយការងារគឺប្រសើរជាងការបរិភោគនៅក្នុងបន្ទប់សម្រាក បើសិនជាការបរិភោគនៅបន្ទប់តូច ឬស្ថានីយការងារផ្តល់ជូនគំលាតកាន់តែធំ និងរបាំងរវាងបុគ្គលិក។
- ❑ ចំនួនមនុស្សត្រូវបានកាត់បន្ថយ ហើយគំលាតរវាងបុគ្គលិក ត្រូវបានបង្កើនជាអតិបរមានៅក្នុងបន្ទប់ ឬកន្លែងនានាដែលបុគ្គលិកប្រើសម្រាប់បរិភោគអាហារនិង/ឬសម្រាក។ ចំណុចនេះត្រូវបានសម្រេចដោយៈ
  - ○ បិទប្រកាសកំណត់ចំនួនមនុស្សអតិបរមាដែលអនុញ្ញាតឲ្យមានការរក្សាគំលាតយ៉ាងតិចប្រាំមួយហ្វីតរវាងបុគ្គលនៅក្នុងបន្ទប់ឬកន្លែងដែលប្រើសម្រាប់ការសម្រាក
  - ○ ឆ្លាស់ម៉ោងសម្រាក ឬម៉ោងបរិភោគអាហារ ដើម្បីកាត់បន្ថយចំនួនមនុស្សនៅក្នុងបន្ទប់ ឬទីកន្លែងដែលប្រើសម្រាប់ការបរិភោគអាហារ និងសម្រាក និង
  - ○ ដាក់តុឃ្លាតពីគ្នាប្រាំមួយហ្វីត និងធានាបាននូវគំលាតប្រាំមួយហ្វីតរវាងកន្លែងអង្គុយ ដោយដកកៅអី ឬបិទបង់ស្អិតលើកៅអីដើម្បីកាត់បន្ថយចំនួនមនុស្ស ដាក់គ្រឿងសំគាល់លើកម្រាលឥដ្ឋដើម្បីធានាបាននូវការរក្សាគំលាត និងរៀបចំកន្លែងអង្គុយតាមរបៀបមួយដែលកាត់បន្ថយការប៉ះពាល់ទល់មុខគ្នា។ ការប្រើប្រាស់របាំងខណ្ឌចែក ត្រូវបានលើកទឹកចិត្តដើម្បីទប់ស្កាត់ការរីករាលដាលបន្ថែមទៀត ប៉ុន្តែមិនគួរចាត់ទុកថាជាវិធីជំនួសឲ្យការកាត់បន្ថយចំនួនមនុស្ស និងការរក្សាគំលាតរាងកាយឡើយ។
- ❑ បុគ្គលិក អ្នកម៉ៅការនៅនឹងកន្លែង អ្នកលក់ និងបុគ្គលិកដឹកជញ្ជូនទាំងអស់បានទទួលការណែនាំទាក់ទងនឹងការរក្សាគំលាតរាងកាយ និងការប្រើប្រាស់របាំងមុខដែលចាំបាច់ពេលនៅជិតអ្នកដទៃ។
- ❑ បន្ទប់សម្រាក បន្ទប់ទឹក បន្ទប់រៀន និងទីកន្លែងទូទៅផ្សេងទៀតដែលត្រូវបានប្រើ ឬចូលដោយបុគ្គលិក ត្រូវបានសម្លាប់មេរោគជាញឹកញាប់ ទៅតាមកាលវិភាគដូចខាងក្រោមៈ
  - ○ បន្ទប់សម្រាក ____________________________________________
  - ○ បន្ទប់ទឹក ____________________________________________
  - ○ បន្ទប់រៀន ____________________________________________
  - ○ មន្ទីរពិសោធន៍ ____________________________________________
  - ○ ការិយាល័យគិលានុបដ្ឋាយិកា ____________________________________________
  - ○ ទីកន្លែងប្រឹក្សាយោបល់ ឬជំនួយសិស្សផ្សេងទៀត __________________________
  - ○ ការិយាល័យខាងមុខ ____________________________________________
  - ○ ការិយាល័យផ្សេងទៀត ____________________________________________
  - ○ ផ្សេងទៀត (សាលប្រជុំ កន្លែងហាត់ប្រាណ បណ្ណាល័យបើសិនជាប្រើប្រាស់) _____________
  - ○ ________________________________________________________
- ❑ ទីកន្លែងដែលមានការប៉ះពាល់ច្រើននៅក្នុងបន្ទប់សម្រាករបស់បុគ្គលិក ត្រូវបានសម្លាប់មេរោគជាញឹកញាប់ ហើយវត្ថុដែលប្រើរួមគ្នាទូទៅ ដូចជាប៉ាន់កាហ្វេ ឆ្នាំងនិងចាន ត្រូវបានជំនួសដោយវត្ថុប្រើបានតែម្តង ឬត្រូវបានសម្អាតយ៉ាងដិតដល់បន្ទាប់ពីការប្រើម្តងៗដោយមនុស្សផ្សេងគ្នា។
- ❑ សារធាតុសម្លាប់មេរោគ និងការផ្គត់ផ្គង់ដែលពាក់ព័ន្ធគឺមានសម្រាប់បុគ្គលិកនៅទីតាំងដូចខាងក្រោមៈ

______________________________________________________________

- ❑ ទឹកអនាម័យលាងដៃដែលមានប្រសិទ្ធភាពប្រឆាំងជំងឺ COVID-19 គឺមានសម្រាប់បុគ្គលិកទាំងអស់ នៅក្នុងឬជិតទីតាំងដូចខាងក្រោម (គូសធីកទាំងអស់ដែលអនុវត្ត)
  - ○ ច្រកចូលឬច្រកចេញ អគារ
  - ○ ការិយាល័យកណ្តាល
  - ○ ច្រកឡើងជណ្តើរ
  - ○ ច្រកចូលជណ្តើរយន្ត (បើមាន)
  - ○ បន្ទប់រៀន
  - ○ បន្ទប់សម្រាករបស់មន្ត្រី

- ការិយាល័យមន្ត្រី៖ ____________________

- ❑ សាប៊ូ និងទឹកគឺមានសម្រាប់បុគ្គលិកទាំងអស់នៅទីតាំងដូចខាងក្រោម៖

____________________

- ❑ បុគ្គលិកមានឱកាសលាងដៃរបស់ខ្លួនជាញឹកញាប់។
- ❑ បុគ្គលិកនីមួយៗត្រូវបានកំណត់ឧបករណ៍ផ្ទាល់ខ្លួន ការផ្គត់ផ្គង់ បរិក្ខារ និងលំហធ្វើការដែលបានកំណត់ទៅតាមកម្រិតដែលអាចធ្វើបាន។ ការប្រើប្រាស់កន្លែងធ្វើការនិងវត្ថុដែលបានប៉ះរួមគ្នា ត្រូវបានកាត់បន្ថយ ឬលុបបំបាត់។
- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅបុគ្គលិកទាំងអស់។
- ❑ ស្រេចចិត្ត—ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

____________________

## B. វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយដោយបុគ្គលិក សិស្ស និងភ្ញៀវ (គូសធីកទាំងអស់ដែលអនុវត្ត)

- ❑ ចំនួនបុគ្គលិកអតិបរមាដែលត្រូវបានអនុញ្ញាតនៅទីកន្លែង ដើម្បីបង្កើនការរក្សាគំលាតរាងកាយយ៉ាងតិច 6 ហ្វីត ឬដោយមានរបាំងសមស្របនៅពេលដែលមិនអាចរក្សាគំលាត 6 ហ្វីតបាន គឺ៖__________។
- ❑ ចំនួនសិស្សអតិបរមាត្រូវបានអនុញ្ញាតនៅទីកន្លែង ដើម្បីធានាថាមិនមានសិស្សច្រើនជាង 10% នៃសិស្សសរុបក្នុងពេលណាមួយ និងដើម្បីបង្កើនការរក្សាគំលាតរាងកាយយ៉ាងតិច 6 ហ្វីត ឬដោយមានរបាំងពិតសមស្របនៅពេលដែលមិនអាចរក្សាគំលាត 6 ហ្វីតបាន គឺ៖ __________។
- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការរក្សាគំលាតរាងកាយរបស់សិស្សនៅលើរថយន្តក្រុងរបស់សាលា។ វិធានការណ៍ទាំងនេះមានដូចជា (គូសធីកទាំងអស់ដែលអនុវត្ត)៖
  - ជាអតិបរមា កុមារម្នាក់ក្នុងកៅអីមួយលើរថយន្តក្រុង។
  - ចាំបាច់ត្រូវពាក់របាំងមុខនៅគ្រប់ពេលវេលា។
  - ការប្រើប្រាស់ជួរឆ្លាស់គ្នា (ត្រូវបានណែនាំយ៉ាងមុតមាំ ប៉ុន្តែមិនចាំបាច់)។
  - បើកបង្អួច (បើសិនជាគុណភាពខ្យល់ និងការព្រួយបារម្ភអំពីសុវត្ថិភាពអ្នកជិះអនុញ្ញាត ជាពិសេសបើសិនជាជួរឆ្លាស់គ្នាមិនត្រូវបានអនុវត្ត)។

- ❑ ប្រើវិធានការណ៍បន្ថែមដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ (គូសធីកទាំងអស់ដែលអនុវត្ត)៖
  - ដាក់ម៉ោងចូលរៀនឆ្លាស់គ្នា ដើម្បីអនុញ្ញាតឲ្យមានការធ្វើដំណើរច្រើនជាងមួយដងក្នុងរថយន្តក្រុងមួយ នៅពេលសាលារៀនចាប់ផ្តើម និងបិទ។
  - ការអនុវត្តវិធានការណ៍ដែលធ្វើឲ្យមានភាពងាយស្រួលសម្រាប់ឲ្យឪពុកម្តាយបើកយានយន្តជូនសិស្សមកសាលា ដូចជាការឆាប់បើកសាលា ដោយមានវត្តមានបុគ្គលិក ការចតយានយន្តរយៈពេលខ្លីដែលបានពង្រីកបន្ថែមនៅសាលា និងវត្តមានបុគ្គលិកនៅកន្លែងដាក់សិស្សចុះ ដើម្បីធានាបាននូវបម្លាស់ទីមានសុវត្ថិភាពរបស់សិស្សពីកន្លែងចុះមកកាន់ច្រកចូលសាលា។
  - ការអនុវត្តវិធានការណ៍ដែលសម្រួលដល់ការធ្វើដំណើរដោយមានសុវត្ថិភាព និងសមស្របតាមវ័យសម្រាប់សិស្សមកកាន់សាលារៀន ដូចជាក្រុមថ្មើរជើង ផ្លូវមានសុវត្ថិភាពមកកាន់សាលារៀន (Safe Routes to School) មានអ្នកជួយឆ្លងផ្លូវចូលសាលា កម្មវិធីសុវត្ថិភាពកង់ និងផ្លូវជិះកង់។
    - ឪពុកម្តាយត្រូវបានរៀបចំឲ្យធ្វើការជាមួយបុគ្គលិកសាលា ដើម្បីប្រាកដថាមានជម្រើសមធ្យោបាយធ្វើដំណើរផ្សេងទៀត ដែលមានការគ្រប់គ្រងសមស្រប និងមានយុទ្ធសាស្ត្រដែលបានរួមបញ្ចូលសម្រាប់ការរក្សាគំលាតរាងកាយ និងការប្រើប្រាស់ក្រណាត់បាំងមុខ។
  - ហេដ្ឋារចនាសម្ព័ន្ធអគារត្រូវបានសម្រួល ដើម្បីបង្កើនជំនួយដល់ការធ្វើដំណើរដោយជិះកង់ និងកន្លែងផ្ទុកកង់ត្រូវបានបង្កើនបើអាចធ្វើបាន។
  - ផ្សេងទៀត៖

____________________

- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ នៅពេលដែលសិស្ស ឪពុកម្តាយ

ឬភ្ញៀវចូល ឬដើរឆ្លងកាត់អគារសាលារៀន។ មានដូចជា (គូសធីកទាំងអស់ដែលអនុវត្ត)៖

- កាលវិភាគត្រូវបានលៃតម្រូវដើម្បីធានាថាមានតែមួយក្រុមប៉ុណ្ណោះ ដែលកំពុងដើរកាត់ទីកន្លែងទូទៅ (ដូចជាផ្លូវកាត់អគារ ឬបន្ទប់ទឹក) នៅពេលដែលបានផ្តល់ឲ្យ។
- បុគ្គលិកសាលាត្រូវបានដាក់ឲ្យប្រចាំការនៅផ្លូវដើរក្នុងអគារ ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយនៅពេលដែលសិស្សចូល ឆ្លងកាត់ការត្រួតពិនិត្យរោគសញ្ញា និងដើរទៅកាន់បន្ទប់រៀន។
- បើអាចអនុវត្តបាន ចំណុះផ្ទុកនៃជណ្តើរយន្តត្រូវបានដាក់កម្រិតត្រឹមចំនួនមនុស្សដែលអាចសម្រួលបាន ខណៈដែលរក្សាគំលាត 6 ហ្វីតរវាងអ្នកជិះម្នាក់ៗ។ ក្នុងអំឡុងម៉ោងចូល និងចេញពីអគារដែលមានមនុស្សច្រើន ចំនួននេះអាចត្រូវបានកែតម្រូវឲ្យមានអ្នកជិះច្រើនបំផុត 4 នាក់ក្នុងម្តងសម្រាប់ជណ្តើរយន្តទាំងឡាយណាដែលមិនអនុញ្ញាតឲ្យមានគំលាតរាងកាយ 6 ហ្វីតរវាងអ្នកជិះម្នាក់។ អ្នកជិះទាំងអស់ត្រូវបានតម្រូវឲ្យពាក់ក្រណាត់បាំងមុខ។
- វិធានការណ៍ខាងក្រោមត្រូវបានអនុវត្តដើម្បីចៀសវាងការកកស្ទះនៅលើជណ្តើរ៖
  - បង្ហាញទិសដៅទៅជណ្តើរឡើង និងចុះ ____
  - ការសម្រាកឆ្លាស់គ្នារវាងថ្នាក់រៀន ____
  - ការត្រួតពិនិត្យជណ្តើរដោយបុគ្គលិកសាលា ____
  - ផ្សេងទៀត៖ ________________________________________________

❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការរក្សាគំលាតរាងកាយនៅក្នុងបន្ទប់រៀន។ មានដូចជា (គូសធីកទាំងអស់ដែលអនុវត្ត)៖

❑ វិធីសាស្ត្រដាក់ជាក្រុមត្រូវបានអនុវត្តទូទាំងសាលា ដោយរក្សាក្រុមដែលមានស្ថិរភាពមិនឲ្យមានកុមារ ឬយុវជនលើសពី 12 នាក់ និងមិនឲ្យមានមនុស្សធំគ្រប់គ្រងលើសពីពីរនាក់នៅក្នុងបរិយាកាសដែលបានគ្រប់គ្រងដែលមនុស្សធំគ្រប់គ្រង និងកុមារស្ថិតនៅជាមួយគ្នាសម្រាប់គ្រប់សកម្មភាពទាំងអស់ (ឧ. បរិភោគអាហារ ការលំហែ ។ល។) និងចៀសវាងការប៉ះពាល់ជាមួយមនុស្សនៅក្រៅក្រុមរបស់ពួកគេនៅក្នុងទីកន្លែងចាប់ពីផ្តើមរហូតដល់ចប់ថ្ងៃសិក្សា។ (មនុស្សធំគ្រប់គ្រងម្នាក់អាចត្រូវបានចាត់តាំងសម្រាប់ក្រុមដែលមានស្ថិរភាព 2 ខុសៗគ្នាបាន បើសិនជាពួកគេផ្តល់សេវាកម្ម/ជំនួយឯកទេសដែលមនុស្សធំគ្រប់គ្រងផ្សេងទៀតមិនអាចផ្តល់ជូនបាន។)

- ទំហំថ្នាក់ដែលសិស្សចូលរៀនផ្ទាល់ ត្រូវបានកំណត់ឲ្យមានសិស្សត្រឹម ___ នាក់នៅថ្នាក់បឋមសិក្សា។
- ទំហំថ្នាក់ដែលសិស្សចូលរៀនផ្ទាល់ ត្រូវបានកំណត់ឲ្យមានសិស្សត្រឹម ___ នាក់នៅថ្នាក់មធ្យមសិក្សា និងវិទ្យាល័យ។
- ថ្ងៃសិក្សាត្រូវបានបំបែកទៅជាវេនដើម្បីអនុញ្ញាតឲ្យមានចំនួនសិស្សតិចជាងមុនក្នុងមួយថ្នាក់។
- វត្តមានត្រូវបានធ្វើឲ្យឆ្លាស់គ្នាដើម្បីកាត់បន្ថយចំនួនសិស្សជារួមនៅក្នុងបន្ទប់រៀននៅថ្ងៃតែមួយ។
- ថ្នាក់មួយចំនួនត្រូវបានផ្លាស់ទីទៅអនឡាញទាំងស្រុង។
- វត្តមានក្នុងថ្នាក់តាមអនឡាញ ត្រូវបានផ្តល់ជូនជាជម្រើសសម្រាប់សិស្សទាំងអស់ សម្រាប់ថ្នាក់ទាំងអស់។
- ទីកន្លែងផ្សេងទៀតត្រូវបានប្រើដើម្បីកាត់បន្ថយចំនួនសិស្សនៅក្នុងបន្ទប់រៀន។ អាចមានដូចជា៖
  - បណ្ណាល័យសាលា ____
  - សាលប្រជុំ ____
  - អាហារដ្ឋាន ____
  - កន្លែងហាត់ប្រាណ ____
  - ផ្សេងទៀត៖ ________________________________
- គ្រឿងសង្ហារឹមក្នុងបន្ទប់រៀន ត្រូវបានរៀបចំដើម្បីធានាបាននូវគំលាត 6 ហ្វីតរវាងសិស្សនៅតុរបស់ខ្លួន និងរវាងសិស្សនិងគ្រូ (ការដាក់តុ ការប្រើការសម្គាល់លើកម្រាលឥដ្ឋដើម្បីចង្អុលបង្ហាញពីគំលាតដែលចាំបាច់ ។ល។) ទៅតាមកម្រិតដែលអាចធ្វើបាន។ នៅពេលដែលមិនអាចរក្សាគំលាត 6 ហ្វីតបានត្រូវប្រើរបាំងរាងកាយដើម្បីកាត់បន្ថយការប៉ះពាល់ជិតស្និទ្ធ។
- គ្រឿងសង្ហារឹមដែលបានរចនាសម្រាប់សកម្មភាពជាក្រុមនៅក្នុងថ្នាក់ដែលនាំសិស្សឲ្យមកជិតគ្នាជាង 6 ហ្វីតត្រូវបានរៀបចំឡើងវិញ ឬយកចេញពីបន្ទប់រៀន។
- កន្លែងសម្រាក ឬគេងក្នុងបន្ទប់រៀនត្រូវដាក់ឲ្យសិស្សឃ្លាតពីគ្នា 6 ហ្វីត និងឆ្លាស់គ្នារវាងជើងនិងក្បាល។
- វិធីសាស្ត្របង្រៀនត្រូវបានកែប្រែដើម្បីចៀសវាងការប៉ះពាល់ជិតស្និទ្ធរវាងសិស្ស និងថ្នាក់ផ្សេងៗទៀត

ដែលជាចម្ងាយអាចទាក់ទងនឹងសកម្មភាពជាក្រុម។
- ផ្សេងទៀត៖

  ______________________________________________

- ❑ សកម្មភាពថ្នាក់ហ្វឹកហាត់នៅកន្លែងហាត់ប្រាណទាំងឡាយត្រូវបានផ្តល់ជូននៅក្រៅអគារ និងត្រូវបានជ្រើសរើសដើម្បីអនុញ្ញាតឲ្យមានការរក្សាគំលាតរាងកាយ។ កីឡាដែលមានការប៉ះពាល់គឺមិនត្រូវបានអនុញ្ញាតទេ។
- ❑ គោលការណ៍សាលាអនុវត្តការរក្សាគំលាតរាងកាយ (សិស្សរក្សាគំលាត 6 ហ្វីត) នៅក្នុងបន្ទប់ប្តូរសំលៀកបំពាក់។ គោលការណ៍ត្រូវតែមានដូចជា៖
  - ផ្តល់ការចូលប្រើបន្ទប់ប្តូរសំលៀកបំពាក់នៅពេលដែលមានការគ្រប់គ្រងដោយបុគ្គលិកប៉ុណ្ណោះ ឆ្លាស់ការចូលប្រើបន្ទប់ប្តូរសំលៀកបំពាក់
  - បង្កើតជម្រើសផ្សេងទៀតសម្រាប់ការរក្សាទុកសំលៀកបំពាក់សិស្ស សៀវភៅ និងវត្ថុផ្សេងទៀត។
- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីរក្សាបាននូវការរក្សាគំលាតរាងកាយក្នុងអំឡុងពេលបរិភោគអាហារនៅសាលា។ អាចមានដូចជា (គូសធីកទាំងអស់ដែលអនុវត្ត)៖
  - ម្ហូបអាហារត្រូវបានបរិភោគនៅក្នុងថ្នាក់រៀន ឬខាងក្រៅអគារ ដោយមិនមានការលាយក្រុមចូលគ្នាពីថ្នាក់រៀនខុសគ្នាឡើយ។
  - បើសិនជាសិស្សតម្រង់ជួរយកម្ហូប បង់ស្អិត ឬការសម្គាល់ផ្សេងទៀតត្រូវបានប្រើដើម្បីធានាបាននូវគំលាត 6 ហ្វីតរវាងសិស្សពីរនាក់។
  - បុគ្គលិកត្រូវបានដាក់ឲ្យប្រចាំការក្នុងអំឡុងពេលបរិភោគអាហារ ដើម្បីរក្សាគំលាតរាងកាយនិងរក្សាកុំឲ្យសិស្សថ្នាក់បឋមសិក្សាមកពីបន្ទប់រៀនផ្សេងគ្នាលាយចូលគ្នា។
  - បើសិនជាការបរិភោគអាហារធ្វើឡើងនៅក្នុងអាហារដ្ឋាន ម៉ោងបរិភោគអាហារត្រូវបានកំណត់ឲ្យឆ្លាស់គ្នាដើម្បីអនុញ្ញាតឲ្យមានតែមួយក្រុមប៉ុណ្ណោះនៅក្នុងអាហារដ្ឋានក្នុងពេលម្តង។
  - បើសិនជាការបរិភោគអាហារធ្វើឡើងនៅក្នុងអាហារដ្ឋាន គំលាតរវាងតុ/កៅអីត្រូវបានបង្កើនឡើងដើម្បីគាំទ្រដល់ការរក្សាគំលាតរាងកាយ 6 ហ្វីត។ របាំងរវាងតុ និង/ឬកៅអីអាចត្រូវបានប្រើជាជម្រើសផ្សេងទៀតនៅពេលដែលមិនអាចរក្សាគំលាត 6 ហ្វីតបាន។
- ❑ ការរៀបចំម្ហូបអាហារ និងប្រតិបត្តិការសេវាកម្មត្រូវបានកែប្រែឡើងវិញ នៅពេលដែលអាចធ្វើបាន ដើម្បីសម្រេចបាននូវការរក្សាគំលាតរាងកាយរវាងបុគ្គលិក។ ឧទាហរណ៍ ផ្ទះបាយនិងផ្នែកខាងក្រោយផ្សេងទៀតនៃកម្រាលឥដ្ឋនៅក្នុងអគារ ត្រូវបានគូសសម្គាល់ដើម្បីអនុវត្តសេចក្តីតម្រូវឲ្យរក្សាគំលាតរាងកាយ។
- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីអនុញ្ញាតឲ្យមានការរក្សាគំលាតរាងកាយនៅក្នុងបរិវេណសាលារៀនដែលបានប្រើដោយសេវាកម្មជំនួយសិស្ស។
  - បុគ្គលិកជំនួយសិស្ស ដោយរាប់បញ្ចូលទាំងបុគ្គលិកសាលា (គិលានុបដ្ឋាយិកា ទីប្រឹក្សាណែនាំ គ្រូពេទ្យព្យាបាល ។ល។) និងបុគ្គលិកនៃកម្មវិធីជំនួយបន្ទាប់បន្សំ (គ្រូពេទ្យ អ្នកអប់រំសុខភាព ។ល។) ត្រូវបានណែនាំឲ្យរក្សាគំលាតរាងកាយយ៉ាងតិច 6 ហ្វីតទៅតាមកម្រិតដែលអាចធ្វើបាន ខណៈពេលចូលរួមក្នុងសកម្មភាពជំនួយសិស្ស។
  - គ្រឿងសង្ហារឹម និងបរិក្ខារនៅក្នុងបរិវេណសាលាដែលបានប្រើសម្រាប់សេវាកម្មជំនួយសិស្ស ត្រូវបានរៀបចំដើម្បីលើកកម្ពស់គំលាត 6 ហ្វីតរវាងសិស្សពីរនាក់និង/ឬរវាងសិស្សនិងបុគ្គលិក។
  - នៅពេលដែលអាចធ្វើបាននិងសមស្រប សកម្មភាពជំនួយ និងព្យាបាលត្រូវធ្វើឡើងដោយមិនជួបផ្ទាល់។
  - ការប្រើបរិក្ខារ និងការផ្គត់ផ្គង់រួមគ្នាត្រូវបានចៀសវាងនៅពេលដែលអាចធ្វើបាន។ បើសិនជាចាំបាច់ត្រូវប្រើបរិក្ខាររួមគ្នា ត្រូវតែធ្វើអនាម័យវាមុននិងក្រោយពីការប្រើប្រាស់ម្តងៗដោយសិស្ស និង/ឬបុគ្គលិកខុសៗគ្នា
  - បុគ្គលិកដែលផ្តល់សេវាជំនួយសិស្ស បានទទួល PPE សមស្របតាមសេចក្តីបង្គាប់របស់ Cal OSHA។
- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីអនុញ្ញាតឲ្យមានការរក្សាគំលាតរាងកាយនៅក្នុងទីកន្លែងរដ្ឋបាលរបស់សាលារៀន។
  - ស្លាកសញ្ញាជូនដំណឹងដល់ភ្ញៀវពីភាពចាំបាច់ក្នុងការរក្សាគំលាត 6 ហ្វីតពីបុគ្គលិកបម្រើការងារក្នុងការិយាល័យសាលា។
  - បង់ស្អិត ឬគ្រឿងសម្គាល់ផ្សេងទៀតត្រូវបានប្រើដើម្បីកំណត់រង្វង់ 6 ហ្វីតជុំវិញតុ ឬបញ្ជរទទួលភ្ញៀវ។
  - ស្ថានីយការងាររបស់បុគ្គលិករដ្ឋបាល ត្រូវបានរៀបចំដើម្បីអនុញ្ញាតឲ្យមានគំលាត 6 ហ្វីតរវាងបុគ្គលដែលប្រើទីធ្លារួមគ្នា ឬរវាងបុគ្គលិកការិយាល័យ និងសិស្ស ឬបុគ្គលិកផ្សេងទៀតដែលចាំបាច់ត្រូវចូល

នៅកាន់ទីកន្លែងនោះ។

## C. វិធានការណ៍ដែលធានាបាននូវការគ្រប់គ្រងការឆ្លងជំងឺ (គូសធីកទាំងអស់ដែលអនុវត្តសម្រាប់ទីកន្លែង)

- ❑ ការត្រួតពិនិត្យត្រូវបានធ្វើឡើងមុនពេលដែលសិស្ស ភ្ញៀវ និងបុគ្គលិកអាចចូលមកក្នុងសាលារៀន។ ការត្រួតពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យពាក់ព័ន្ធនឹងរោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 ដែលអាចកើតឡើងនិងរោគសញ្ញាផ្សេងៗទៀតដែលបុគ្គលអាចនឹងកំពុងមាន។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានពីចម្ងាយ (ដោយប្រើកម្មវិធីឌីជីថល ឬវិធីដែលអាចផ្ទៀងផ្ទាត់ផ្សេងទៀត) ឬដោយផ្ទាល់នៅពេលមកដល់។ ការពិនិត្យសីតុណ្ហភាពដោយប្រើទែម៉ូម៉ែត្រមិនបាច់ប៉ះ ត្រូវបានរាប់បញ្ចូលក្នុងការត្រួតពិនិត្យរោគសញ្ញានៅច្រកចូល បើសិនជាអាចធ្វើបាន។
  - សិស្ស បុគ្គលិក និងភ្ញៀវដែលពិនិត្យឃើញថាវិជ្ជមាននៅច្រកចូល ឬដែលរាយការណ៍ពីរោគសញ្ញានៅចំណុចណាមួយក្នុងអំឡុងថ្ងៃសិក្សា នឹងត្រូវបានរាយការណ៍ទៅកាន់ក្រុមការងារអនុលោមភាពជំងឺ COVID-19 (មើលផ្នែក A)។ ក្រុមការងារអនុលោមភាពជំងឺ COVID-19 នឹងធ្វើការសម្រេចថាតើបុគ្គលគួរត្រូវបានបញ្ជូនចេញពីទីកន្លែង ដោយយោងតាមការណែនាំរបស់ DPH ស្តីពីផ្លូវនៃការត្រួតពិនិត្យរោគសញ្ញា និងការប៉ះពាល់ នៅគ្រឹះស្ថានអប់រំឬក៍អត់។ សិស្សដែលត្រួតពិនិត្យឃើញវិជ្ជមានទទួលបានម៉ាស់ពេទ្យ និងនាំទៅកាន់ទីកន្លែងដាក់ឲ្យនៅដាច់ដោយឡែកដែលបានជ្រើសរើសជាមុនដែលពួកគេអាចស្ថិតនៅ ខណៈសេចក្តីសម្រេចត្រូវបានធ្វើឡើងអំពីការបញ្ជូនចេញ និងការរៀបចំត្រូវបានធ្វើឡើងសម្រាប់ឲ្យពួកគេត្រឡប់ទៅផ្ទះ តាមការចង្អុលបង្ហាញ។
  - យោងតាមផ្លូវនៃការត្រួតពិនិត្យរោគសញ្ញា និងការប៉ះពាល់របស់ DPH សិស្ស បុគ្គលិក និងភ្ញៀវដែលបានប៉ះពាល់ជិតស្និទ្ធជាមួយបុគ្គលដែលបានត្រួតពិនិត្យវិជ្ជមានសម្រាប់រោគសញ្ញាដែលដូចគ្នានឹងជំងឺ COVID-19 ដែលអាចកើតឡើង បានទទួលការជូនដំណឹងអំពីការប៉ះពាល់ដែលអាចមាន។ បុគ្គលទាំងនេះ មិនត្រូវបានតម្រូវឲ្យនៅដាច់ពីគេនោះទេ លុះត្រាតែការប៉ះពាល់ត្រូវបានបញ្ជាក់តាមរយៈការធ្វើតេស្តមេរោគវិជ្ជមានសម្រាប់ជំងឺ COVID-19 ឬការធ្វើរោគវិនិច្ឆ័យគ្លីនិកពីអ្នកផ្តល់សេវាវេជ្ជសាស្ត្រ។ សិស្សដែលមានការប៉ះពាល់ដែលបានបញ្ជាក់ ត្រូវបាននាំទៅកាន់ទីកន្លែងនៅដាច់ពីគេដែលបានជ្រើសរើសជាមុន ដែលពួកគេអាចស្ថិតនៅរហូតដល់ការរៀបចំត្រូវបានសម្រាប់ឲ្យពួកគេត្រឡប់ទៅផ្ទះ។ ទីកន្លែងនេះគឺផ្សេងពីទីកន្លែងដែលបានរៀបចំសម្រាប់សិស្សដែលមានរោគសញ្ញា។ វាអាចជាបន្ទប់ដាច់ដោយឡែក ឬទីកន្លែងមួយនៅក្នុងបន្ទប់តែមួយដែលមានរបាំងខ័ណ្ឌចែក។ នៅពេលពួកគេត្រឡប់ទៅផ្ទះ ពួកគេត្រូវបានណែនាំឲ្យដាក់ខ្លួននៅដាច់ពីគេ ដូចបានតម្រូវដោយសេចក្តីបង្គាប់ឲ្យនៅដាច់ពីគេរបស់មន្ត្រីសុខាភិបាល។
- ❑ ការត្រួតពិនិត្យមនុស្សធំ ក៏ដូចជាសិស្សថ្នាក់មធ្យមសិក្សា និងវិទ្យាល័យរាប់បញ្ចូលទាំងសំណួរអំពីការប៉ះពាល់ជិតស្និទ្ធជាមួយនរណាម្នាក់នៅផ្ទះ សាលារៀន ឬកន្លែងផ្សេងទៀតដែលបុគ្គលនោះត្រូវបានប្រាប់ថាបានធ្វើតេស្តជំងឺ COVID-19វិជ្ជមាន ។
  - មនុស្សធំទាំងឡាយដែលត្រូវបានពិនិត្យថាវិជ្ជមាន និងរាយការណ៍ពីការប៉ះពាល់ជិតស្និទ្ធជាមួយមនុស្សឈឺ ត្រូវបានណែនាំឲ្យចាកចេញពីសាលា ត្រឡប់ទៅផ្ទះដើម្បីចាប់ផ្តើមការដាក់ខ្លួនឲ្យនៅដាច់ពីគេ និងធ្វើតេស្តរកជំងឺ COVID-19។
  - សិស្សថ្នាក់មធ្យមសិក្សា ឬវិទ្យាល័យទាំងឡាយដែលត្រូវបានពិនិត្យរកការប៉ះពាល់ និងរាយការណ៍ពីការប៉ះពាល់ជិតស្និទ្ធជាមួយមនុស្សឈឺ បានទទួលម៉ាស់ពេទ្យ និងនាំទៅកន្លែងដាក់ឲ្យនៅដាច់ដោយឡែកដែលបានជ្រើសរើសជាមុននៅក្នុងសាលា ខណៈពេលការរៀបចំ ឲ្យឪពុកម្តាយរបស់ពួកគេមកយក ដើម្បីចាប់ផ្តើមការនៅដាច់ពីគេនៅផ្ទះ។ ឪពុកម្តាយ ត្រូវបានណែនាំឲ្យស្វែងរកការធ្វើតេស្តសម្រាប់កុមារ។
- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីដាក់កម្រិតលើហានិភ័យ (risk) នៃការឆ្លងជំងឺដោយសារការមកជួបដោយបុគ្គលក្រៅពីបុគ្គលិក និងសិស្ស។ អាចមានដូចជា (គូសធីកទាំងអស់ដែលអនុវត្ត)៖
  - ការទៅកាន់សាលារៀនដោយបុគ្គលក្រៅពីបុគ្គលិក និងសិស្សត្រូវតែចៀសវាងនៅគ្រប់ពេលដែលអាចធ្វើបាន។ ឪពុកម្តាយសិស្សដែលបានចុះឈ្មោះ ត្រូវបានលើកទឹកចិត្តឲ្យធ្វើកិច្ចការជាមួយបុគ្គលិកសាលាពីចម្ងាយនៅពេលដែលអាចធ្វើបាន។
  - ភ្ញៀវមកកាន់សាលារៀនក្រៅពីឪពុកម្តាយសិស្សដែលបានចុះឈ្មោះ ត្រូវបានដាក់កម្រិតត្រឹមអ្នកដែលចាំបាច់សម្រាប់ប្រតិបត្តិការសាលារៀន។ ភ្ញៀវគឺមានការណាត់ជួបតែប៉ុណ្ណោះ និងត្រូវបានចុះឈ្មោះជាមុននៅក្នុងកំណត់ត្រាភ្ញៀវ ដែលរួមមានឈ្មោះ លេខទូរស័ព្ទ និងអាសយដ្ឋានអ៊ីមែលរបស់

ភ្ញៀវ។ ភ្ញៀវត្រូវបានណែនាំឲ្យមកតាមការណាត់ជួបរបស់ខ្លួនតែម្នាក់ឯង។ បើសិនជាភ្ញៀវត្រូវតែមានមនុស្សម្នាក់ទៀតមកជាមួយ (ឧ. សម្រាប់ជំនួយបកប្រែ ឬដោយសារភ្ញៀវគឺជាអនីតិជន ឬមានសិស្សតូច) ព័ត៌មានរបស់ពួកគេត្រូវបានកត់ត្រានៅក្នុងកំណត់ត្រាភ្ញៀវ។

- ○ ភ្ញៀវដែលមកដល់សាលាជាមួយនឹងកុមារដែលមិនបានចុះឈ្មោះ (ឧ. ប្អូនរបស់សិស្ស) ត្រូវតែប្រាកដថាកុមារទាំងនេះស្ថិតនៅជិតមនុស្សធំ ចៀសវាងការប៉ះអ្នកដទៃ ឬវត្ថុណាមួយដែលមិនមែនជារបស់ពួកគេ និងត្រូវពាក់ម៉ាស់បើសិនជាមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ និងមិនមានហានិភ័យ (risk) ដោយសារបញ្ហាផ្លូវដង្ហើម។
- ○ ការដើរហើររបស់ភ្ញៀវនៅក្នុងសាលារៀនត្រូវបានដាក់កម្រិតត្រឹមទីកន្លែងដែលបានកំណត់ ដូចជាកន្លែងទទួលភ្ញៀវ ឬកន្លែងរង់ចាំ ការិយាល័យ បន្ទប់សន្និសីទឬបន្ទប់ប្រជុំ និងបន្ទប់ទឹកសាធារណៈទៅតាមកម្រិតដែលអាចធ្វើបាន។ ភ្ញៀវមិនត្រូវបានអនុញ្ញាតឲ្យប្រាស្រ័យទាក់ទងជាមួយក្រុមណាមួយឡើយ។
- ○ ភ្ញៀវដែលមកដល់សាលាត្រូវបានរំលឹកឲ្យពាក់របាំងមុខគ្រប់ពេលវេលាខណៈពេលនៅក្នុងសាលា។ នេះត្រូវអនុវត្តចំពោះមនុស្សពេញវ័យទាំងអស់ និងចំពោះកុមារអាយុ 2 ឆ្នាំឡើងទៅ។ មានតែបុគ្គលដែលត្រូវបានណែនាំមិនឲ្យពាក់របាំងមុខដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ពួកគេប៉ុណ្ណោះដែលត្រូវបានលើកលែងពីការពាក់របាំងមុខនេះ។ ដើម្បីគាំទ្រដល់សុវត្ថិភាពបុគ្គលិករបស់អ្នក និងភ្ញៀវផ្សេងទៀត របាំងមុខគួរត្រូវបានផ្តល់ជូនដល់ភ្ញៀវដែលមកដល់ហើយគ្មានម៉ាស។

☐ វិធានការណ៍ត្រូវបានអនុវត្តដើម្បីលើកកម្ពស់ខ្យល់ចេញចូលល្អបំផុតនៅក្នុងសាលារៀន។ អាចមានដូចជា (គូសធីកទាំងអស់ដែលអនុវត្ត)៖

- ○ យ៉ាងតិច 50% នៃបន្ទប់សិក្សា ម្ហូបអាហារ និងសកម្មភាពត្រូវបានប្តូរទៅខាងក្រៅអគារ នៅគ្រប់ពេលដែលអាកាសធាតុអំណោយផល។
- ○ ប្រព័ន្ធ HVAC របស់សាលាត្រូវដំណើរការល្អធម្មតា។
- ○ ប្រព័ន្ធ HVAC ត្រូវបានកំណត់ឲ្យបង្កើនការផ្លាស់ប្តូរខ្យល់ក្នុង/ក្រៅអគារជាអតិបរមា លុះត្រាតែស្ថានភាពខាងក្រៅ (ទើបមានអគ្គីភ័យថ្មីៗ សីតុណ្ហភាពខាងក្រៅក្តៅខ្លាំង មានលំអងផ្កាច្រើន ។ល។) ធ្វើឲ្យមិនសមស្រប។
- ○ ត្រូវដំឡើងម៉ាស៊ីនសម្អាតខ្យល់ចល័ត មានប្រសិទ្ធភាពខ្ពស់ បើសិនជាអាចធ្វើបាន។
- ○ ទ្វារនិងបង្អួចត្រូវបានបើកចំហក្នុងអំឡុងថ្ងៃសិក្សា បើសិនជាអាចធ្វើបាន និងបើសិនជាស្ថានភាពខាងក្រៅអំណោយផលដល់ការធ្វើបែបនេះ។
- ○ តម្រងខ្យល់ត្រូវបានដំឡើងឲ្យមានប្រសិទ្ធភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន។
- ○ ផ្សេងទៀត៖

  ______________________________________________.

❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការសម្អាត និងការសម្លាប់មេរោគសមស្របទៅលើទីកន្លែង ផ្ទៃនិងវត្ថុនៅក្នុងសាលារៀនទាំងមូល។ អាចមានដូចជា (គូសធីកទាំងអស់ដែលអនុវត្ត)។

- ○ កាលវិភាគសម្អាតនិងសម្លាប់មេរោគត្រូវបានបង្កើតឡើងដើម្បីចៀសវាងការប្រើប្រាស់ផលិតផលសម្អាតដែលកំពុងប្រើប្រាស់តិចជាងនិងលើសកំរិត។
- ○ រថយន្តក្រុងត្រូវបានសម្អាតនិងសម្លាប់មេរោគយ៉ាងជិតដល់ជារៀងរាល់ថ្ងៃ និងក្រោយពីដឹកជញ្ជូនបុគ្គលណាមួយដែលកំពុងចេញរោគសញ្ញាជំងឺ COVID-19។ តែកុងមានបំពាក់នៅក្រដាសជូតសម្លាប់មេរោគ និងស្រោមដៃប្រើហើយអាចបោះចោលបាន ដើម្បីជំនួយដល់ការសម្លាប់មេរោគលើផ្ទៃតាមការចាំបាច់ក្នុងអំឡុងពេលកំពុងធ្វើការ។  ផ្ទៃដែលបានប៉ះពាល់ជាញឹកញាប់ត្រូវបានសម្លាប់មេរោគបន្ទាប់ពីបញ្ចប់ការជិះរថយន្តក្រុងម្តងៗ។
- ○ ទីកន្លែងទូទៅ និងវត្ថុដែលបានប៉ះពាល់ជាញឹកញាប់នៅក្នុងទីកន្លែងទាំងនោះ (តុ ដៃទ្វារ កុងតាក់ភ្លើង ផ្ទៃតុធ្វើការ ដៃកាន់ តុ ទូរស័ព្ទ ក្តារចុច កុងតាក់និងប៊ូតុងជណ្តើរយន្ត អេក្រង់ចុចម៉ាស៊ីនបោះពុម្ព/ម៉ាស៊ីនថតចម្លង របារកាន់ និងបង្កាន់ដៃ) ត្រូវបានសម្លាប់មេរោគយ៉ាងហោចណាស់រាល់ថ្ងៃ និងញឹកញាប់ជាងនេះ នៅពេលដែលធនធានអនុញ្ញាតឲ្យប្រើផលិតផលដែលសមស្រប (មើលខាងក្រោម)។
- ○ ការប្រើវត្ថុរួមគ្នាត្រូវបានបញ្ឈប់គ្រប់ពេលដែលអាចធ្វើបាន ឧទាហរណ៍ទឹកបាញ់ត្រូវបានបិទ ហើយដបទឹកផ្ទាល់ខ្លួនត្រូវបានផ្តល់ជាជម្រើស សម្ភារៈសួនកម្សាន្តដែលមានការប៉ះពាល់ច្រើនអាចត្រូវបានយកចេញ និងជំនួសដោយល្បែងក្នុងសួនកម្សាន្តដែលមិនបាច់ប៉ះ។ល។
- ○ នៅកន្លែងដែលជម្រើសបុគ្គលមិនអាចធ្វើបាន ឧទាហរណ៍ នៅក្នុងមន្ទីរពិសោធន៍និងបន្ទប់សិល្បៈ ដែលបរិក្ខារមួយចំនួនអាចត្រូវបានប្រើដោយសិស្សច្រើននាក់ វត្ថុនិងផ្ទៃត្រូវបានសម្អាតនិងសម្លាប់មេរោគរវាងអ្នកប្រើ។

- ផលិតផលសម្អាតដែលមានប្រសិទ្ធភាពប្រឆាំងនឹងជំងឺ COVID-19 (មាននៅលើបញ្ជីបានអនុម័ត "N" ដោយភ្នាក់ងារការពារបរិស្ថាន (EPA)) ត្រូវបានប្រើដោយយោងទៅតាមការណែនាំរបស់ផលិតផល។ នៅពេលដែលមិនមានសារធាតុសម្លាប់មេរោគដែលបានអនុម័តដោយ EPA សារធាតុសម្លាប់មេរោគជម្រើសផ្សេងទៀតអាចត្រូវបានប្រើប្រាស់ (ឧទាហរណ៍ 1/3 ពែងនៃ bleach ដាក់ទៅក្នុងទឹក 1 ហ្គាឡុង ឬស្វូលុយស្យុងអាល់កុល 70%)។ កុំលាយ bleach ឬផលិតផលសម្អាតនិងសម្លាប់មេរោគផ្សេងទៀតចូលគ្នា - វាអាចបណ្តាលឲ្យមានផ្សែងពុលដែលមានគ្រោះថ្នាក់ខ្លាំងណាស់ក្នុងការដកដង្ហើម។
- បុគ្គលិកថែទាំ ឬបុគ្គលិកផ្សេងទៀតដែលទទួលខុសត្រូវចំពោះការសម្អាតនិងការសម្លាប់មេរោគផ្ទៃនិងបរិក្ខាក្នុងសាលា បានទទួលការបណ្តុះបណ្តាលអំពីការណែនាំរបស់ក្រុមហ៊ុនផលិត សេចក្តីតម្រូវ Cal/OSHA សម្រាប់ការប្រើដោយសុវត្ថិភាពនិងដូចបានតម្រូវដោយច្បាប់ស្តីពីសាលារៀនមានសុខភាពល្អ (Healthy Schools Act) តាមការដែលអាចអនុវត្តបាន។
- បុគ្គលិកថែទាំ និងបុគ្គលិកផ្សេងទៀតដែលទទួលខុសត្រូវចំពោះការសម្អាតនិងការសម្លាប់មេរោគត្រូវបានបំពាក់ដោយឧបករណ៍ការពារផ្ទាល់ខ្លួន ដូចជាស្រោមដៃ ការការពារភ្នែក ការការពារផ្លូវដង្ហើម និងឧបករណ៍ការពារសមស្របផ្សេងទៀតតាមតម្រូវការផលិតផល។
- ផលិតផលសម្អាតទាំងអស់ត្រូវតែដាក់ឲ្យផុតពីដៃក្មេងនិងស្តុកនៅក្នុងកន្លែងដែលមិនសូវមានការប៉ះពាល់។
- ខ្យល់ចេញចូលត្រូវបានបង្កើនជាអតិបរមា ក្នុងអំឡុងពេលសម្អាតនិងសម្លាប់មេរោគទៅតាមកម្រិតដែលអាចធ្វើបាន បើសិនជាប្រើម៉ាស៊ីនត្រជាក់ ចូរប្រើការកំណត់ដែលនាំចូលខ្យល់បរិសុទ្ធ។ ប្តូរនិងពិនិត្យមើលតម្រងខ្យល់និងប្រព័ន្ធច្រោះដើម្បីធានាបាននូវគុណភាពខ្យល់ល្អបំផុត។
- ការសម្អាតដែលធ្វើឲ្យប្រសើរឡើងត្រូវបានធ្វើនៅពេលដែលសិស្សមិននៅសាលា ដោយមានពេលវេលាគ្រប់គ្រាន់ដើម្បីទុកឲ្យខ្យល់ចេញមុនពេលចាប់ផ្តើមថ្ងៃសិក្សា។
- ជំហានត្រូវបានអនុវត្តដើម្បីធានាថាប្រព័ន្ធទឹកនិងចានកន្ទន់ទាំងអស់គឺមានសុវត្ថិភាពសម្រាប់ប្រើប្រាស់ បន្ទាប់ពីទីកន្លែងបិទទ្វារក្នុងរយៈពេលយូរ ដើម្បីកាត់បន្ថយហានិភ័យ (risk) នៃជំងឺ Legionnaires និងជំងឺផ្សេងទៀតដែលទាក់ទងនឹងទឹក។
- បន្ទប់ទឹក កន្លែងរង់ចាំ បន្ទប់សម្រាក ក៏ដូចជាកន្លែងអង្គុយលេង និងទីកន្លែងទូទៅផ្សេងទៀតកំពុងត្រូវបានសម្លាប់មេរោគជាញឹកញាប់ទៅតាមកាលវិភាគដូចខាងក្រោម៖
  - បន្ទប់ទឹក៖ ______________________________
  - កន្លែងចូល/កន្លែងរង់ចាំ៖ ______________________________
  - បន្ទប់សម្រាករបស់គ្រូបង្រៀន/បុគ្គលិក៖ ______________________________
  - បន្ទប់រៀន ______________________________
  - ទីកន្លែងបរិភោគនៅអាហារដ្ឋាន ______________________________
  - កន្លែងរៀបចំម្ហូបអាហារនៅអាហារដ្ឋាន ______________________________
  - ការិយាល័យខាងមុខ ______________________________
  - ការិយាល័យផ្សេងទៀត ______________________________
  - ទីកន្លែងផ្សេងទៀត ______________________________

❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការប្រើប្រាស់របាំងមុខដែលសមស្របដោយបុគ្គលិក សិស្ស និងភ្ញៀវទាំងអស់នៅគ្រប់ពេលវេលា។ អាចមានដូចជា (គូសធីកទាំងអស់ដែលអនុវត្ត)៖

- បុគ្គលិក ឪពុកម្តាយ និងសិស្សបានទទួលព័ត៌មានអំពីសេចក្តីបង្គាប់ឲ្យពាក់ក្រណាត់បាំងមុខមុនពេលចាប់ផ្តើមសាលារៀននិងជាប្រចាំនៅក្នុងឆ្នាំសិក្សាទាំងមូល។
- សិស្សទាំងអស់ដែលមានអាយុលើស 2 ឆ្នាំ តម្រូវឲ្យពាក់ក្រណាត់បាំងមុខនៅគ្រប់ពេលវេលាខណៈពេលនៅក្នុងបរិវេណសាលាលើកលែងពេលបរិភោគ ផឹក ឬធ្វើសកម្មភាពផ្សេងទៀតដែលរារាំងដល់ការពាក់របាំងមុខ។
- យុទ្ធសាស្ត្រការពារផ្សេងទៀតអាចត្រូវបានអនុវត្តដើម្បីសម្រួលដល់សិស្សដែលស្ថិតនៅក្នុងការអប់រំមានលក្ខណៈបុគ្គល ឬផែនការ 504 និងដែលមិនអាចប្រើឬទ្រាំនឹងក្រណាត់បាំងមុខបាន។
- ព័ត៌មានត្រូវបានផ្តល់ឲ្យបុគ្គលិក ឪពុកម្តាយ និងសិស្សទាក់ទងនឹងការប្រើប្រាស់ក្រណាត់បាំងមុខបានសមស្រប ដោយរាប់បញ្ចូលទាំងការចាំបាច់ក្នុងការបោកគក់ក្រណាត់បាំងមុខបន្ទាប់ពីការប្រើប្រាស់ក្នុងមួយថ្ងៃៗ។
- ស្លាកសញ្ញានៅច្រកចូលសាលា នៅច្រកចូលការិយាល័យសាលា និងទូទាំងអគារសាលាទាំងមូលពង្រឹងសេចក្តីបង្គាប់នេះ និងរៀបរាប់ពីការប្រើប្រាស់ក្រណាត់បាំងមុខត្រឹមត្រូវ។

- តាមដែលអាចធ្វើបាន ក្រណាត់បាំងមុខពីរត្រូវបានផ្តល់ឲ្យសិស្សនីមួយៗនៅពេលចាប់ផ្តើមឆ្នាំសិក្សា។ បើសិនជាមិនអាចធ្វើដូច្នោះបាន ឪពុកម្តាយនិងសិស្សបានទទួលព័ត៌មានទាក់ទងនឹងវិធីធ្វើក្រណាត់បាំងមុខដោយខ្លួនឯង។
- ឪពុកម្តាយកុមារតូច ត្រូវបានលើកទឹកចិត្តឲ្យផ្តល់របាំងមុខទីពីរដល់សាលារៀនជារៀងរាល់ថ្ងៃ ក្នុងករណីដែលរបាំងមុខដែលកុមារកំពុងពាក់ប្រឡាក់ នេះនឹងអនុញ្ញាតឲ្យមានការផ្លាស់ប្តូររបាំងមុខនៅក្នុងថ្ងៃសិក្សា។
- បុគ្គលិកត្រូវបានដាក់ឲ្យប្រចាំការនៅច្រកចូលសាលា ឬនៅផ្លូវដើរក្នុងអគារ ឬទីកន្លែងទូទៅផ្សេងទៀតដើម្បីពង្រឹងការរក្សាគំលាតរាងកាយ ក៏ដូចជាដើម្បីរំលឹកសិស្សអំពីវិន័យពាក់ព័ន្ធនឹងការប្រើប្រាស់ក្រណាត់បាំងមុខផងដែរ។
- បុគ្គលិកដែលចូលរួមក្នុងសកម្មភាព (ដូចជាការផ្តល់ការព្យាបាលរាងកាយ ឬជំនួយផ្ទាល់ខ្លួនដល់សិស្សម្នាក់ៗ) ដែលមិនអាចរក្សាគំលាតរាងកាយបាន ត្រូវបានបំពាក់ទៅដោយសម្ភារៈការពារផ្ទាល់ខ្លួនសមស្រប (ស្រោមដៃ ម៉ាស់ អាវការពារ ។ល។) តាមការគួរ។
- បុគ្គលិកដែលថែទាំសិស្សឈឺ បានទទួលម៉ាស់កម្រិតវេជ្ជសាស្ត្រដើម្បីពាក់ដោយខ្លួនឯង និងម៉ាស់កម្រិតវេជ្ជសាស្ត្រសម្រាប់ឲ្យសិស្សពាក់ (បើសិនជាសិស្សអាចពាក់បាន) រហូតដល់សិស្សចាកចេញពីអគារ។

**កំណត់សម្គាល់៖** បុគ្គលិក និងសិស្សដែលនៅម្នាក់ឯងក្នុងការិយាល័យបិទជិត បន្ទប់តូចមានជញ្ជាំង ឬទីកន្លែងឯកជនបិទជិតផ្សេងទៀត មិនតម្រូវឲ្យពាក់ក្រណាត់បាំងមុខឡើយ។ សិស្សក៏អាចដោះក្រណាត់បាំងមុខនៅពេលបរិភោគអាហារ ឬគេង ឬពេលដែលមិនអាចពាក់ក្រណាត់បាំងមុខបាន (ឧ. ពេលងូតទឹក ។ល។)។ សាលាក៏អាចពិចារណាថា តើគ្រូបង្រៀននៅថ្នាក់សិស្សតូចៗសមស្របនឹងប្រើសន្ទះបាំងមុខប្លាស្ទិកដោយមានក្រណាត់រុំខាងក្រោមចង្កាជាការជំនួសឲ្យក្រណាត់បាំងមុខ ដើម្បីឲ្យសិស្សតូចៗអាចមើលឃើញមុខគ្រូរបស់ខ្លួន និងដើម្បីចៀសវាងការរាំងស្ទះដែលអាចកើតឡើងដល់ការបង្រៀនសូរស័ព្ទ។

❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការលាងដៃជាញឹកញាប់ដោយបុគ្គលិក សិស្ស និងភ្ញៀវ។ វាអាចមានដូចជា (គូសធីកទាំងអស់ដែលអនុវត្ត)៖

- សិស្ស និងបុគ្គលិកមានឱកាសញឹកញាប់ដើម្បីលាងដៃរបស់ខ្លួនរយៈពេល 20 វិនាទីជាមួយសាប៊ូ ដោយដុសឲ្យបានសព្វល្អ និងប្រើប្រាស់កន្សែង (ឬក្រណាត់កន្សែងដែលប្រើតែម្តង) ដើម្បីជូតដៃឲ្យស្ងួតល្អ។ ក្រុមនីមួយៗត្រូវបានតម្រូវឲ្យប្រើបន្ទប់ទឹកដែលបានកំណត់។ បើសិនជាមានសិស្សច្រើនជាងមួយក្រុមត្រូវបានកំណត់ឲ្យប្រើបន្ទប់ទឹកតែមួយ ប្រព័ន្ធកូដពណ៌ត្រូវបានប្រើដើម្បីកាត់បន្ថយសិស្សមកពីក្រុមផ្សេងទៀតប្រើប្រាស់បន្ទប់ទឹកក្នុងពេលតែមួយ។
- សិស្សតូចៗ ត្រូវបានកំណត់កាលវិភាគជាប្រចាំសម្រាប់ការសម្រាកលាងដៃចាំបាច់ ដោយរាប់បញ្ចូលទាំងមុននិងក្រោយពេលបរិភោគ បន្ទាប់ពីប្រើបង្គន់ បន្ទាប់ពីលេងនៅខាងក្រៅ ក៏ដូចជាមុននិងក្រោយពីសកម្មភាពជាក្រុមផ្សេងៗ។
- បុគ្គលិកត្រូវបានណែនាំឲ្យធ្វើគំរូលាងដៃជាញឹកញាប់ ជាពិសេសនៅថ្នាក់តូចដែលពេលវេលាប្រើបន្ទប់ទឹក គឺជាឱកាសដើម្បីពង្រឹងទម្លាប់មានសុខភាពល្អ និងត្រួតពិនិត្យការលាងដៃដែលសមស្រប។
- ទីកន្លែងលាងដៃចល័ត ត្រូវបានដាក់នៅជិតបន្ទប់រៀន ដើម្បីកាត់បន្ថយការដើរហើរ និងការប្រមូលផ្តុំនៅក្នុងបន្ទប់ទឹកទៅតាមកម្រិតដែលអាចអនុវត្តបាន។
- ទឹកអនាម័យលាងដៃដែលមានជាតិអាល់កុលអេទីល (មានអេតាណុលយ៉ាងតិច 60%) គឺមានសម្រាប់សិស្ស និងបុគ្គលិកនៅតាមទីតាំងយុទ្ធសាស្ត្រក្នុងសាលាទាំងមូល ដែលមិនមានកន្ទន់ ឬទីកន្លែងលាងដៃចល័ត (នៅក្នុង ឬជិតបន្ទប់រៀន បន្ទប់ដែលផ្តល់សេវាជំនួយ បន្ទប់តន្ត្រី និងសិល្បៈ)។ ទឹកអនាម័យលាងដៃដែលមានជាតិអាល់កុលអេទីល គឺជាជម្រើសប្រសើរជាងនិងគួរត្រូវបានប្រើនៅក្នុងបរិស្ថានសាលារៀន។ ទឹកអនាម័យលាងដៃដែលមានអ៊ីសូប្រូពីលអាល់កុលជាធាតុផ្សំសកម្មមិនត្រូវបានប្រើនៅតាមសាលារៀនឡើយ ព្រោះវាធ្វើឲ្យរោលស្បែកនិងអាចជ្រាបចូលទៅក្នុងស្បែក។
- ការលេបទឹកអនាម័យលាងដៃដែលមានជាតិអាល់កុល អាចបណ្តាលឲ្យមានការពុលជាតិអាល់កុល។ ទឹកអនាម័យលាងដៃមិនមានដាក់នៅទីចំហនិងគួរត្រូវបានប្រើដោយមានការគ្រប់គ្រងពីមនុស្សធំសម្រាប់កុមារអាយុក្រោម 9 ឆ្នាំ។ មន្ត្រីនិងបុគ្គលិកត្រូវបានប្រាប់ឲ្យដឹងពីហានិភ័យ (risk) នៃការលេបនិងថាពួកគេគួរទូរស័ព្ទទៅផ្នែកគ្រប់គ្រងការពុល (Poison Control) តាមរយៈលេខ 1-800-222-1222 បើសិនជាមានហេតុផលដែលជឿថាសិស្សបានលេបទឹកអនាម័យលាងដៃ។
- ទឹកអនាម័យលាងដៃ សាប៊ូនិងទឹក ក្រដាសជូតមាត់និងធុងសម្រាម គឺមានសម្រាប់សាធារណៈជននៅ ឬក្បែរច្រកចូលនៃទីកន្លែង ឬនៅកន្លែងទទួលភ្ញៀវ និងគ្រប់ទីកន្លែងផ្សេងទៀតនៅខាងក្នុងកន្លែងធ្វើការ ឬខាងក្រៅដែលមនុស្សមានការប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់។

❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការគ្រប់គ្រងការឆ្លងជំងឺនៅក្នុងអាហារដ្ឋានសាលា ឬទីកន្លែងផ្សេងទៀតដែលមានបម្រើ ឬទៅយកម្ហូបអាហារ។
  - ម្ហូបអាហារបែបប៊ូហ្វេ និងលក្ខណៈគ្រួសារត្រូវបានលុបបំបាត់។
  - ជម្រើសម្ហូបអាហាររួមបញ្ចូលទាំងម្ហូបអាហារដែលបានវេចខ្ចប់ជាមុន អាហារក្តៅដែលបម្រើដោយបុគ្គលិកអាហារដ្ឋាន និង/ឬម្ហូបអាហារដែលសិស្សយកមកពីផ្ទះ។
  - របាំងការពាររាងកាយត្រូវបានប្រើនៅពេលចាំបាច់ដើម្បីដាក់កម្រិតលើការប៉ះពាល់រវាងបុគ្គលិកអាហារដ្ឋាននិងសិស្ស។
  - ស្រេចចិត្ត-ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

______________________________________________________________________

## D. វិធានការណ៍ដែលទំនាក់ទំនងជាមួយសហគមន៍សាលារៀន និងសាធារណៈជន

❑ ព័ត៌មានត្រូវបានផ្ញើទៅកាន់ឪពុកម្តាយ និងសិស្សមុនពេលចាប់ផ្តើមសាលារៀនពាក់ព័ន្ធនឹងគោលការណ៍សាលារៀនដែលទាក់ទងនឹង (គូសធីកទាំងអស់ដែលអនុវត្ត)៖
  - គោលការណ៍ដាក់ខ្លួនឲ្យនៅដាច់ដោយឡែក និងដាក់ខ្លួនឲ្យនៅដាច់ពីគេ នៅពេលដែលពួកគេអនុវត្តលើសិស្សដែលមានរោគសញ្ញា ឬអាចនឹងបានប៉ះពាល់ជាមួយជំងឺ COVID-19 _____
  - ជម្រើសសម្រាប់ការធ្វើតេស្តជំងឺ COVID-19 បើសិនជាសិស្ស ឬសមាជិកគ្រួសារមានរោគសញ្ញា ឬបានប៉ះពាល់ជាមួយជំងឺ COVID-19 _____
  - អ្នកដែលត្រូវទាក់ទងនៅសាលារៀន បើសិនជាសិស្សមានរោគសញ្ញា ឬអាចនឹងត្រូវបានប៉ះពាល់ _____
  - របៀបធ្វើការពិនិត្យរោគសញ្ញាមុនពេលសិស្សចេញពីផ្ទះ _____
  - តម្រូវឲ្យប្រើរបាំងមុខ _____
  - សារៈសំខាន់នៃការអនុវត្តរបស់សិស្សក្នុងការរក្សាគំលាតរាងកាយ និងគោលការណ៍គ្រប់គ្រងការឆ្លងជំងឺ _____
  - ការផ្លាស់ប្តូរនៅក្នុងកម្មវិធីសិក្សានិងសកម្មភាពក្រៅកម្មវិធីសិក្សា ដើម្បីបញ្ចៀសហានិភ័យ (risk) _____
  - ការផ្លាស់ប្តូរម្ហូបអាហារនៅសាលារៀនដើម្បីបញ្ចៀសហានិភ័យ (risk) _____
  - គោលការណ៍សាលាទាក់ទងនឹងការមកកាន់សាលាដោយឪពុកម្តាយ និងការប្រឹក្សាយោបល់អំពីការទាក់ទងសាលារៀនពីចម្ងាយ _____
  - សារៈសំខាន់នៃការផ្តល់ព័ត៌មានទំនាក់ទំនងករណីបន្ទាន់ដល់សាលារៀនរួមទាំងជម្រើសច្រើនដើម្បីទំនាក់ទំនងឪពុកម្តាយ _____
  - ផ្សេងទៀត៖

______________________________________________________

❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទាំងអស់មកក្នុងសាលារៀន។

❑ ស្លាកសញ្ញាត្រូវបានបិទផ្សាយនៅក្នុងសាលារៀនទាំងមូលដែលរំលឹកបុគ្គលិក និងសិស្សអំពីគោលការណ៍ទាក់ទងនឹងការរក្សាគំលាតរាងកាយ ការប្រើប្រាស់របាំងមុខ និងសារៈសំខាន់នៃការលាងដៃ។

❑ ស្លាកសញ្ញាត្រូវបានបិទផ្សាយនៅច្រកចូលសាធារណៈនីមួយៗរបស់សាលាដែលរំលឹកដល់ភ្ញៀវថាពួកគេមិនគួរចូលក្នុងទីកន្លែងឡើយ បើសិនជាពួកគេមានរោគសញ្ញាជំងឺ COVID-19។

❑ សាលាបានបង្កើតនិងផ្សព្វផ្សាយផែនការទំនាក់ទំនងក្នុងករណីចាំបាច់ត្រូវបិទទាំងស្រុង ឬដោយផ្នែកដោយសារករណីជំងឺ COVID-19 ជាចង្កោមដែលអាចកើតឡើង។

- ❑ ប្រកអនឡាញនៃសាលារៀន (គេហទំព័រ បណ្តាញសង្គម ។ល។) ផ្តល់ព័ត៌មានច្បាស់លាស់អំពីម៉ោងអគារ គោលការណ៍មកទស្សនា ការផ្លាស់ប្តូរកម្មវិធីសិក្សា និងសកម្មភាពក្រៅកម្មវិធីសិក្សា និងការតម្រូវឲ្យប្រើរបាំងមុខ ការរក្សាគំលាតរាងកាយ និងការលាងដៃ។
- ❑ ប្រកអនឡាញណែនាំសិស្ស ឪពុកម្តាយ និងគ្រូបង្រៀនអំពីរបៀបទាក់ទងសាលារៀនក្នុងករណីដែលមានការឆ្លងជំងឺ ឬការប៉ះពាល់។

## E. វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

- ❑ ផែនការសម្រាប់ការធ្វើបច្ចុប្បន្នភាព ផែនការអប់រំលក្ខណៈបុគ្គល (IEPs) និងផែនការ 504 របស់សិស្សដែលមានតម្រូវការពិសេស ត្រូវបានបង្កើតឡើងដើម្បីធានាបានថាការអប់រំអាចបន្តទៅបានដោយមិនមានហានិភ័យ (risk) ហួសហេតុដល់សិស្ស។
  - ផែនការនេះរាប់បញ្ចូលវិធីសាស្ត្រសម្រាប់ការទំនាក់ទំនងសកម្មជាមុនជាមួយឪពុកម្តាយនៅដើមឆ្នាំសិក្សា ដើម្បីធានាថាបញ្ហាទាក់ទងនឹងការអប់រំ និងសុវត្ថិភាពកុមារកំពុងត្រូវបានដោះស្រាយ។
  - ការកែប្រែទៅលើ IEPs និងផែនការ 504 អាចទាក់ទងនឹងការសិក្សាពីចម្ងាយ ការកែប្រែទៅលើបន្ទប់រៀនដើម្បីសម្រួលដល់តម្រូវការសិស្ស ការមានវត្តមាននៅសាលារៀននៅក្នុងតំបន់ដាច់ដោយឡែកដែលមានសិស្សតិច ឬវិធីហ៊ាយប្រ៊ីត(hybrid)ដោយរួមបញ្ចូលការសិក្សានៅក្នុងថ្នាក់និងការសិក្សាពីចម្ងាយ។
  - ជំហានដែលបានអនុវត្តដើម្បីកែប្រែ IEPs និងផែនការ 504 ដើម្បីធានាថាសិស្សអនុវត្តតាមបទប្បញ្ញត្តិដែលពាក់ព័ន្ធនៃច្បាប់រដ្ឋ និងច្បាប់សហព័ន្ធ។
- ❑ សេវាកម្ម ឬប្រតិបត្តិការរដ្ឋបាលដែលអាចត្រូវបានផ្តល់ជូនពីចម្ងាយ (ឧ. ការចុះឈ្មោះក្នុងថ្នាក់ ការដាក់ទម្រង់បែបបទ ។ល។) ត្រូវបានផ្លាស់ប្តូរទៅជាអនឡាញ។

**វិធានការណ៍បន្ថែមទាំងឡាយដែលខុសពីខាងលើ គួរត្រូវបានរាយនៅលើទំព័រដាច់ដោយឡែក ដែលអាជីវកម្មគួរភ្ជាប់ជាមួយឯកសារនេះ។**

**អ្នកអាចទាក់ទងបុគ្គលខាងក្រោមជាមួយសំណួរ ឬមតិអំពីពិធីការនេះ៖**

**ឈ្មោះទំនាក់ទំនងអាជីវកម្ម៖** ______________________

**លេខទូរស័ព្ទ៖** ______________________

**កាលបរិច្ឆេទកែសម្រួលចុងក្រោយ៖** ______________________